មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ការវិភាគផ្លូវច្បាប់លើសំណុំរឿងព្រហ្មទណ្ឌប្រឆាំងនឹងអតីតអភិបាលក្រុងបាវិតលោក ឈូក បណ្ឌិត និងនាយនគរបាលលោក ស ចាន់ថា ក្នុងករណីបាញ់ប្រហារលើកម្មការិនី រោងចក្រកៅវ៉េ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២

## ១. សេចក្តីផ្តើម

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ លោក ឈូក បណ្ឌិត អតីតអភិបាលក្រុងបាវិត ("ជនជាប់ចោទ") ត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាពពីបទ *"បង្ករបួសស្នាមដោយអចេតនា"* ("បទចោទ") តាមមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ("ក្រមព្រហ្មទណ្ឌ") ហើយត្រូវបានតុលាការផ្តន្ទាទោសកំបាំងមុខដាក់ពន្ធនាគាររយៈពេល ១៨ ខែ និងបង្គាប់ឲ្យបង់ប្រាក់សំណងសរុប ៣៨ លានរៀល[1] (ប្រមាណជា ៩.៥០០ ដុល្លារអាមេរិក)។ [2] បទចោទប្រឆាំងនឹងជនជាប់ចោទត្រូវបានធ្វើឡើងដោយផ្អែកលើការចោទប្រកាន់ដែលថា លោក ឈូក បណ្ឌិត បានបាញ់កាំភ្លើងសំដៅទៅលើក្រុមបាតុករនៅរោងចក្រកៅវ៉េ ស្ពត លីមីដធីត ("រោងចក្រកៅវ៉េ") កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ("ករណីបាញ់ប្រហារ") ដែលបង្កឲ្យកម្មការិនីរោងចក្របីនាក់រងរបួសធ្ងន់ រួមមាន៖ កែវ នា អាយុ ១៩ ឆ្នាំ ប៊ុន ចិន្តា អាយុ ២១ ឆ្នាំ និង នុត សាខន អាយុ ២៣ ឆ្នាំ ("ជនរងគ្រោះ")។[3]

បើទោះជាមានភស្តុតាងគួរឲ្យទុកជឿជាក់ រួមទាំងការទទួលស្គាល់ថាបានប្រើប្រាស់កាំភ្លើងដោយលោក ឈូក បណ្ឌិត នៅពេលដែលខ្លួនបានទៅប្រឈមជាមួយនឹងកម្មកររោងចក្រក្តី ជនជាប់ចោទបានត្រូវសាលាដំបូងខេត្តស្វាយរៀងបានទម្លាក់ចោលបទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនេះ [4] ហើយក្រោយមកត្រូវបានសាលាឧទ្ធរណ៍បង្គាប់ឲ្យបន្តនីតិវិធីសវនាការលើសំណុំរឿងនេះ ដែលសាលាដំបូងការខេត្តបានផ្តន្ទាទោសលោក ឈូក បណ្ឌិត ពីបទ *"បង្ករបួសស្នាមដោយអចេតនា"*។ ជនជាប់ចោទបានលះបង់សិទ្ធិមានវត្តមាននៅពេលជំនុំ

---

[1] ២០លានរៀលផ្តល់ជូន ប៊ុន ចិន្តា ១០លានរៀលផ្តល់ជូន នុត សាខន និង៨លានរៀលផ្តល់ជូន កែវ នា។

[2] សុ ជីវី សាមាន យុន និង ចូសៅ លីប៉េស 'អតីតអភិបាលក្រុងបាវិតទទួលទោសជាប់ពន្ធនាគារ១៨ខែ ក្នុងករណីបាញ់ប្រហារ' *វិទ្យុអាស៊ីសេរី* (ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣) អាចរកបានតាម៖www.rfa.org/english/news/cambodia/verdict-06252013165812.html។

[3] សមាគមសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍កម្ពុជា ("អាដហុក") 'សង្គមស៊ីវិលព្រួយបារម្ភពីសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ចំពោះការស៊ើបអង្កេតជាថ្មីលើបទចោទប្រកាន់ឈូក បណ្ឌិត នៅសាលាដំបូងខេត្ត' (ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣) អាចរកបានតាម៖ www.adhoc-cambodia.org/?p=3058 ។

[4] ម៉ៃ ទិត្យធារ៉ា និង អាប៊ី សេហ្វ 'ឈូក បណ្ឌិត ត្រូវបានតុលាការទម្លាក់ការចោទប្រកាន់' កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១២)។

ជម្រះដោយខ្លួនឯង ដែលឈានដល់ការផ្តន្ទាទោសលើរូបគាត់ ហើយរហូតមកដល់ពេលនេះ ជនជាប់ចោទមិនទាន់បានអនុវត្តទោសរបស់ខ្លួន ឬក៏សងសំណងជំងឺចិត្តដែលតុលាការបានសម្រេចដល់ជនរងគ្រោះនៅឡើយនោះទេ ដោយសារតែជនជាប់ចោទកំពុងព្យាយាមគេចខ្លួនពីអាជ្ញាធរ។[5]

ជនជាប់ចោទត្រូវបានតុលាការចោទប្រកាន់ស្របជាមួយនឹងលោក ស ចាន់ថា ("សហជនជាប់ចោទ") នាយនគរបាលព្រហ្មទណ្ឌខេត្តស្វាយរៀង ដែលត្រូវបានតុលាការលើកលែងការចោទប្រកាន់ពីបទ "*បង្ករបួសស្នាមដោយអចេតនា*" ប៉ុន្តែត្រូវបានផ្តន្ទាទោសពីបទ "*ប្រើប្រាស់អាវុធខុសច្បាប់*" ដែលផ្ទុយនឹងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ និងគ្រឿងផ្ទុះ ហើយត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ ខែ និងពិន័យជាប្រាក់ចំនួន ១ លានរៀល (ប្រមាណជា ២៥០ ដុល្លារអាមេរិក)។[6]

ទោះបីជាអាជ្ញាធរខកខានមិនបានចាប់ខ្លួនជនជាប់ចោទយ៉ាងណាក្តី លោក ឈូក បណ្ឌិត នៅតែត្រូវបានអនុញ្ញាតឲ្យប្តឹងជំទាស់ទៅនឹងការចោទប្រកាន់ និងការផ្តន្ទាទោសលើរូបគាត់។ [7] សេចក្តីសម្រេចរបស់សាលាដំបូងខេត្តស្វាយរៀងក៏ត្រូវបានប្តឹងឧទ្ធរណ៍ដោយសហជនជាប់ចោទ និងជនរងគ្រោះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ សាលាឧទ្ធរណ៍បានបើកសវនាការឧទ្ធរណ៍ ("សវនាការឧទ្ធរណ៍") របស់ជនជាប់ចោទទាំងពីររូប និងដើមបណ្តឹងរដ្ឋប្បវេណី ហើយជនជាប់ចោទបានជ្រើសរើសមិនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជាថ្មីម្តងទៀត។ ថ្វីបើអវត្តមាននៅក្នុងសវនាការក្តី ក៏ជនជាប់ចោទមានមេធាវីការពារក្តីរបស់ខ្លួននៅសវនាការឧទ្ធរណ៍ ហើយតាមរយៈនេះ មេធាវីការពារក្តីជនជាប់ចោទបានបំភ្លឺថាលោក ឈូក បណ្ឌិត មិនមានទំនួលខុសត្រូវណាមួយចំពោះករណីបាញ់ប្រហារនោះឡើយ ហើយបានព្យាយាមទម្លាក់កំហុសដាក់អ្នកដទៃដែលមានវត្តមាននៅរោងចក្រកៅវ៉េ កាលពីព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០១២។[8]

កាលពីថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ សាលាឧទ្ធរណ៍បានចេញសេចក្តីសម្រេចនៅពេលសវនាការឧទ្ធរណ៍ និងបានតម្កល់សេចក្តីសម្រេចផ្តន្ទាទោសលើជនជាប់ចោទពីបទ "*បង្ករបួសស្នាមដោយអចេតនា*" និងសហជនជាប់ចោទពីបទ "*ប្រើប្រាស់អាវុធខុសច្បាប់*" ទុកជាបានការដដែល។ លោកចៅក្រម តាំង ស៊ុនឡាយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍ បានថ្លែងអំពីសម្អាងហេតុ ដែលសាលាឧទ្ធរណ៍ធ្វើការតម្កល់សាលក្រមពីបទ "បង្ករបួសស្នាមដោយអចេតនា" នេះ គឺដោយសារជនជាប់ចោទពុំដែលស្គាល់ជនរងគ្រោះ ហើយក៏

---

5 វ៉ាន់ វាចា សាមៀន យុន និង វ៉ាឈេល វ៉ានដេនប្រីង 'អតីតអភិបាលក្រុងបាវិត កំពុងគេចខ្លួន' *វិទ្យុអាស៊ីសេរី* (ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០១៣) អាចរកបានតាម៖www.rfa.org/english/news/cambodia/chhouk-bandith-07032013190621.html។

6 សេចក្តីថ្លែងការណ៍របស់សមាគម អាដហុក៖ ការផ្តន្ទាទោសលើ ឈូក បណ្ឌិត គ្មានន័យខ្លឹមសារ ប្រសិនបើគាត់នៅមានសេរីភាព' (ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣) អាចរកបានតាម៖ www.adhoc-cambodia.org/?p=3727។

7 ម៉ៃ ទិត្យជារ៉ា 'បណ្ឌិតប្តឹងឧទ្ធរណ៍ខណៈដែលកំពុងគៀសខ្លួន' កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣)។

8 ខៃ សុវុទ្ធី 'បណ្ឌិត មិនបានបង្ហាញខ្លួនអស់រយៈពេលពីរឆ្នាំហើយ បន្ទាប់ពីបាញ់កម្មការិនីកាត់ដេរ' កាសែត *ដឹ ខេម បូឌា* (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣) អាចរកបានតាម៖ <www.cambodiadaily.com/news/bundith-still-a-no-show-20-months-after-garment-workers-shot-46453/។

មិនធ្លាប់មានទំនាស់នឹងគ្នាពីមុនមកទេ។ តែយ៉ាងណាក្តី រឿងនេះត្រូវគេជឿយ៉ាងទូលំទូលាយថា បទចោទប្រកាន់លើជនជាប់ចោទនោះ មិនបានឆ្លុះបញ្ចាំងពីស្ថានទម្ងន់នៃការបាញ់ប្រហារនោះទេ[9] ហើយការស្នាក់ស្ទើរក្នុងការចោទប្រកាន់ឲ្យបានត្រឹមត្រូវ ព្រមទាំងការខកខានជាបន្តបន្ទាប់ក្នុងការចាប់ខ្លួនជនជាប់ចោទ បង្ហាញឲ្យឃើញពី កង្វះអព្យាក្រឹត្យភាពរបស់អាជ្ញាធរ នៅពេលចាត់ការលើករណីពាក់ព័ន្ធជាមួយនឹងបុគ្គលដែលមានទំនាក់ទំនងស្និទ្ធជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល")។

## ២. ខ្លឹមសារសង្ខេប

ការវិភាគផ្លូវច្បាប់នេះរួមមាន៖ (១) ផ្តល់នូវសាវតារជាក់លាក់ចំពោះការចាប់ខ្លួន ការចោទប្រកាន់ និងការផ្តន្ទាទោសទៅលើជនជាប់ចោទ និងសហជនជាប់ចោទ (២) ធ្វើការវិភាគជាដំណាក់ៗ លើការចោទប្រកាន់ និងលើកយកច្បាប់មកសម្អាងលើអង្គហេតុដូចដែលត្រូវបានរាយការណ៍ ដែលផ្តល់ទឡ្ហីករណ៍ដែលថាច្បាប់ត្រូវបានអនុវត្តពុំត្រឹមត្រូវ ដោយពិនិត្យពិចារណាលើភស្តុតាងដែលមាន (៣) ពិនិត្យមើលលើនីតិវិធីរបស់តុលាការទាំងនៅដំណាក់កាលមុនការជំនុំជម្រះ ដំណាក់កាលជំនុំជម្រះ និងដំណាក់កាលសវនាការឧទ្ធរណ៍ ព្រមទាំងពិនិត្យឃើញថា មានការរំលោភបំពានមួយចំនួនលើច្បាប់អន្តរជាតិដែលមានអាទិភាពលើសវនាការតុលាការ (៤) ផ្តល់នូវទិដ្ឋភាពទូទៅនៃសិទ្ធិមនុស្សជាសារវ័ន្តដែលត្រូវបានបំពានដោយជនជាប់ចោទ ពោលគឺ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំរបស់ជនរងគ្រោះ និង (៥) ធ្វើការសន្និដ្ឋានលើការចោទប្រកាន់ និងការផ្តន្ទាទោសមិនជួនល្មមនឹងអំពើរបស់ជនជាប់ចោទ បង្ហាញពីការកាត់សេចក្តីខុសទាំងស្រុងរបស់តុលាការ។

អត្ថបទវិភាគផ្លូវច្បាប់នេះ តាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការឈានមុខ មិនមែនរដ្ឋាភិបាល ឯករាជ្យ មិនប្រកាន់និន្នាការនយោបាយ ("អង្គការ") ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ភស្តុតាង និងព័ត៌មានលម្អិតនៃនីតិវិធីជំនុំជម្រះនៅសាលាដំបូងខេត្តស្វាយរៀង ត្រូវបានទទួលពីប្រភពច្បាប់ដែលបានពិគ្រោះដោយ ម.ស.ម.ក ដែលស្នើសុំមិនបញ្ចេញអត្តសញ្ញាណ។ ព័ត៌មានលម្អិតនៃនីតិវិធីនៅសាលាឧទ្ធរណ៍បានមកពីក្រុមការងារសង្កេតសវនាការរបស់ ម.ស.ម.ក ផ្ទាល់។

## ៣. អង្គហេតុ

### កូដកម្មនៅរោងចក្រកៅវ៉េ

រោងចក្រកៅវ៉េមានទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ("តំបន់សេដ្ឋកិច្ច") ខេត្តស្វាយរៀង ដែល

---

[9] សុជីវី សាមៀន យុន និង ចូសៅ លីប៉េស ' អតីតអភិបាលក្រុងបាវិតទទួលទោសជាប់ពន្ធនាគាររយៈពេល១៨ខែ ក្នុងករណីបាញ់ប្រហារ' វិទ្យុអាស៊ីសេរី (ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣) អាចរកបានតាម៖ www.rfa.org/english/news/cambodia/verdict-06252013165812.html ។

ប្រមូលផ្តុំរោងចក្រកាត់ដេរចំនួន ៤ ហើយដែលកូដកម្មត្រូវបានធ្វើឡើងជាបន្តបន្ទាប់នៅក្នុងសប្តាហ៍ ដែលឈានដល់ករណីបាញ់ប្រហារតែម្តង។ កម្មករបានធ្វើការទាមទារឲ្យមានលក្ខខណ្ឌការងារល្អប្រសើរ ទាមទារឲ្យបន្ថែមប្រាក់ឧបត្ថម្ភចំនួន ៥០ សេន (ប្រមាណជា ២.០០០ រៀល) ក្នុង ១ ថ្ងៃ សម្រាប់ថ្លៃម្ហូបអាហារ និងបន្ថែម ១០ ដុល្លារអាមេរិក ក្នុង ១ ខែសម្រាប់ថ្លៃធ្វើដំណើរ។[10] កម្មកររោងចក្រកៅវ៉េ ក៏បានទាមទារឲ្យមានលក្ខខណ្ឌការងារប្រសើរពីជនជាប់ចោទផងដែរ ដែលពេលនោះកូដកម្មនៅមិនទាន់កើតមាននៅឡើយទេ។ ទោះបីជាយ៉ាងនេះក្តី កូដកម្មកន្លងមកដែលបានកើតឡើងនៅក្នុងតំបន់សេដ្ឋកិច្ចមានការចូលរួមពីកម្មកររាប់ពាន់នាក់ និងបានប្រព្រឹត្តទៅដោយមិនមានអំពើហិង្សា ឬឧប្បត្តិហេតុអ្វីនោះទេ។ នៅក្នុងអំឡុងពេលនៃការតវ៉ាពាក់ព័ន្ធនឹងកូដកម្មចាប់ពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ នៅ រោងចក្រ ស្ប៉េក្សូ រោងចក្រ ឃីង ម៉េកឃើ និងរោងចក្រ បេស្ទវ៉េ (រោងចក្រទាំងអស់នេះស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ច) នគរបាលបានប្រើប្រាស់ឧស្ម័នបង្ហូរទឹកភ្នែកដំបង ប្រឆាំងនឹងកម្មករដែលចោទថាបានគប់ដុំថ្ម និងបង្កការខូតខាតដល់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅតំបន់នោះ។ ក្រោយមក នគរបាល រួមទាំងសហជនជាប់ចោទផង ត្រូវបានបញ្ជូនទៅឲ្យបំពេញភារកិច្ចនៅតំបន់សេដ្ឋកិច្ចអំឡុងពេលកូដកម្ម ប៉ុន្តែ ពួកគេត្រូវបានណែនាំមិនឲ្យប្រើប្រាស់អាវុធ និងគ្រឿងផ្ទុះដែលប៉ះពាល់ដល់អាយុជីវិតប្រឆាំងនឹងកម្មករនោះទេ។

## ការបាញ់ប្រហារ

នៅព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ជនរងគ្រោះបានទៅដល់កន្លែងធ្វើការនៅរោងចក្រកៅវ៉េ នៅម៉ោងប្រហែល ៧:២០ នាទីព្រឹក ហើយបានចូលទៅក្នុងបរិវេណរោងចក្រ។ ខុសប្លែកពីថ្ងៃធម្មតា ជនរងគ្រោះបានឃើញនគរបាលជាច្រើនការពារនៅតំបន់កើតហេតុ ហើយត្រូវបានប្រាប់ថា ជនជាប់ចោទមានបំណងបិទរោងចក្រកៅវ៉េនៅថ្ងៃនោះ ក្នុងគោលបំណងដើម្បីបញ្ចៀសការតវ៉ានៅរោងចក្រ។ ជនរងគ្រោះ និងកម្មករដទៃទៀតដែលបានមកដល់រោងចក្រតាមវេនធ្វើការរបស់ខ្លួននៅថ្ងៃនោះត្រូវបានស្នើឲ្យចាកចេញពីរោងចក្រ។ តែយ៉ាងណាក៏ដោយ កម្មកររោងចក្រកៅវ៉េនៅតែបន្តមកដល់រោងចក្រ ដែលកម្មករជាច្រើនមានបំណងជួបជាមួយនឹងជនជាប់ចោទដើម្បីពិភាក្សាពីការទាមទាររបស់ពួកគេ។ ជាលទ្ធផល ក្រុមកម្មករជាច្រើននាក់បានប្រមូលផ្តុំគ្នាប៉ែកខាងជើងឆៀងខាងកើតនៃច្រកទ្វារខាងក្រោយរោងចក្រកៅវ៉េ និងនៅជិតបន្ទប់ទឹកដែលមានទីតាំងនៅខាងក្នុងរបងប៉ែកខាងជើងនៃរោងចក្រ។ ជនរងគ្រោះ បានសម្រេចឈរនៅទីតាំងនៃបន្ទប់ទឹកនោះ។ ខណៈដែលក្រុមកម្មករជាទូទៅស្ថិតនៅក្នុងស្ថានភាពស្ងប់ស្ងាត់ មានកម្មករមួយចំនួនបានចោលដុំថ្មទៅលើអាគាររោងចក្រចំនួនបី ដែលនាំឲ្យមេបញ្ជាការនគរបាលនៅទីនោះបានជូនដំណឹងនេះដល់ជនជាប់ចោទនៅម៉ោងប្រហែល ៧:៥៥ នាទីព្រឹក។

---

[10] អាដហុក ៉សង្គមស៊ីវិលព្រួយបារម្ភចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ឲ្យស៊ើបអង្កេតឡើងវិញលើបទចោទប្រកាន់លើ ឈូក បណ្ឌិត នៅសាលាដំបូងខេត្ត (ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣) អាចរកបានតាម៖ http://www.adhoc-cambodia.org/?p=3058

ជនជាប់ចោទបានធ្វើដំណើរតាមរថយន្តចេញពីគេហដ្ឋានរបស់ខ្លួន ដែលស្ថិតនៅក្បែរកន្លែងកើតហេតុ ដោយមានមន្ត្រីរបស់រដ្ឋាភិបាលម្នាក់មកជាមួយផង និងបានមកដល់ច្រកទ្វារខាងក្រោយរោងចក្រកៅវ៉េ នៅម៉ោងប្រហែល ៨:០០ ព្រឹក។ ជនជាប់ចោទបានចុះពីរថយន្តរបស់ខ្លួន ហើយបាននិយាយយ៉ាងខ្លីជាមួយនគរបាលនៅទីនោះ មុនពេលឃើញថាក្រុមកម្មករកំពុងតែប៉ុនប៉ងកម្ទេចកាមេរ៉ាថតវីដេអូចំនួនបីគ្រឿងដែលបំពាក់នៅលើអាគាររោងចក្រកៅវ៉េ។ រំពេចនោះ ក្នុងគោលបំណងដើម្បីបញ្ឈប់សកម្មភាពរបស់កម្មករ ជនជាប់ចោទបានដើរចូលទៅកាត់ក្រុមកូដករតាមច្រកចូលខាងក្រោយអាគាររោងចក្រ ដោយបានស្រែកប្រកាសអោយកម្មករដកថយ។ ខណៈដែលជនជាប់ចោទបានធ្វើដំណើរឆ្ពោះទៅរកកម្មករ គាត់មានកាំភ្លើងខ្លីជាប់នឹងខ្លួន។ តាមសាក្សីពីខាងតំណាងអយ្យការបានផ្តល់សក្ខីកម្មថា ជនជាប់ចោទបានយកកាំភ្លើងពីគេហដ្ឋានទៅជាមួយ។ ជនជាប់ចោទបានសារភាពថាខ្លួនមានកាំភ្លើង ប៉ុន្តែកាំភ្លើងដែលគាត់យកទៅកាលពីព្រឹកនៃថ្ងៃកើតមានករណីបាញ់ប្រហារនោះ មិនត្រូវបានរកឃើញទេ ហើយជនជាប់ចោទក៏បានអះអាងទៀតថា ខ្លួន "ចាំមិនបាន" ថាខ្លួនបានប្រគល់កាំភ្លើងនោះទៅឲ្យអ្នកណានោះទេ។ នៅពេលស្ថិតក្នុងចម្ងាយត្រឹមតែប៉ុន្មានម៉ែត្រពីអាគារដែលមានបំពាក់កាមេរ៉ាថតវីដេអូ ជនជាប់ចោទបានបែរមុខដាក់កម្មករ ដោយបានលើកកាំភ្លើងរបស់ខ្លួនឡើង ហើយតាមសម្តីសាក្សីឃើញផ្ទាល់ភ្នែកបាននិយាយថា ជនជាប់ចោទបានបាញ់យ៉ាងហោចណាស់ពីរលើកតម្រង់ឆ្ពោះទៅក្រុមកម្មករ ដែលបណ្តាលឲ្យត្រូវចំជនរងគ្រោះចំនួនបីនាក់នោះតែម្តង។ ជនរងគ្រោះពីរនាក់ក្នុងចំណោមជនរងគ្រោះទាំងបី មិនបានស្ថិតនៅក្នុងក្រុមកម្មករទេ ហើយពួកគេបានឈរនៅក្បែរបន្ទប់ទឹកដែលស្ថិតនៅខាងក្នុងបរិវេណរោងចក្រ។

ជនរងគ្រោះទាំងបីនាក់រងរបួសយ៉ាងធ្ងន់ធ្ងរ ហើយជនរងគ្រោះម្នាក់ឈ្មោះ ប៊ុន ចិន្តា រងរបួសស្ទើរតែបាត់បង់ជីវិត ដោយគ្រាប់កាំភ្លើងបៀមជាប់នឹងដើមទ្រូង។[11] សាក្សីឃើញផ្ទាល់បានផ្តល់សក្ខីកម្មក្រោយមកទៀតថា ជនជាប់ចោទបានព្យាយាមបន្តបាញ់កាំភ្លើងតម្រង់ទៅកាន់ក្រុមកម្មករទៀត តែត្រូវបានអាក់ខានវិញដោយសារកាំភ្លើងនោះជាប់គាំងបាញ់មិនចេញគ្រាប់។

បន្ទាប់ពីបាញ់ហើយ ជនជាប់ចោទបានគេចខ្លួនពីកន្លែងកើតហេតុ ដោយមានជំនួយពីនគរបាលនៅទីនោះ ដោយធ្វើដំណើរចេញពីម្តុំក្បែរបន្ទប់ទឹក និងច្រកទ្វារខាងក្រោយ ហើយចូលតាមផ្លូវចន្លោះអាគារពីរនៅក្នុងរោងចក្រកៅវ៉េ និងបានចេញតាមច្រកទ្វារមុខនៅផ្នែកខាងត្បូងនៃរោងចក្រ។ បន្ទាប់មក ជនជាប់ចោទបានរត់តាមវាលស្រែទៅកាន់ភាគខាងលិចនៃតំបន់សេដ្ឋកិច្ច ហើយក៏មានកម្មករមួយក្រុមបានដេញតាមដែរ។ ក្នុងអំឡុងពេលរត់គេចចេញពីកន្លែងកើតហេតុនៃការបាញ់ប្រហារ ជនជាប់ចោទបានប្រគល់កាំភ្លើងទៅមន្ត្រីនគរ-បាលម្នាក់ក្នុងចំណោមនគរបាលដែលបានជួយជម្លៀសខ្លួនគាត់ចេញពីទីនោះ។ សក្ខីកម្មរបស់សាក្សីឃើញផ្ទាល់ភ្នែកនានាដែលបានថ្លែងថា ការដែលជនជាប់ចោទបានអាក់ខានក្នុងការបាញ់បន្ថែមទៅលើក្រុមកម្មករបន្ត

---

[11] អាដហុក ៉សង្គមស៊ីវិលព្រួយបារម្ភចំពោះសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ឲ្យបើកការស៊ើបអង្កេតឡើងវិញលើបទចោទប្រកាន់ ឈូក បណ្ឌិត នៅសាលាដំបូងខេត្ត (ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣)។

ទៀត មានលក្ខណៈដូចគ្នានឹងកំណត់ហេតុរបស់សាក្សីដែលជានគរបាលម្នាក់ ដែលបានទទួលកាំភ្លើងពីជនជាប់ចោទនៅពេលជនជាប់បានគេចខ្លួន និងជាអ្នកដែលបានផ្តល់ភស្តុតាងអំពីការជាប់គាំងនៃកាំភ្លើងរបស់ជនជាប់ចោទ។ ជនជាប់ចោទ បានភៀសខ្លួនរួចពីក្រុមកម្មករដែលកំពុងដេញតាមគាត់ តែបើទោះជាដូច្នោះក្តី មូលហេតុដែលគាត់អាចគេចចេញបាន នៅតែមិនទាន់ច្បាស់លាស់នៅឡើយ។ បន្ទាប់ពីការបាញ់ប្រហារ ក្រុមកម្មករដែលបានប្រមូលផ្តុំគ្នានៅចំណុចប៉ែកខាងជើង និងប៉ែកខាងជើងឆៀងខាងកើតនៃរោងចក្រកៅវ៉េ បានបញ្ចេញប្រតិកម្មយ៉ាងហិង្សា ដោយបានបំផ្លាញផ្នែកខ្លះនៃអាគាររោងចក្រ និងបានដុតម៉ាស៊ីនភ្លើងឲ្យឆេះ ដែលបានធ្វើឲ្យមានអណ្តាតភ្លើងឆេះសន្ធោសន្ធៅឡើងទៀត។

## សហជនជាប់ចោទ

នៅចំពេលមានការបាញ់ប្រហារ មានអំពើហិង្សាបន្តិចបន្តួចបានកើតឡើងនៅក្នុងអំឡុងពេលកូដកម្មដែលត្រូវបានធ្វើឡើងនៅរោងចក្រ យីងម៉េកឃើ និងរោងចក្រហ្សេកូ ដែលស្ថិតនៅទល់មុខរោងចក្រកៅវ៉េ ប៉ែកខាងកើតនៃតំបន់សេដ្ឋកិច្ច។

ពុំមានការបញ្ជាក់ច្បាស់លាស់ណាមួយពីការជាប់ទាក់ទិនគ្នារវាងសហជនជាប់ចោទ និងជនជាប់ចោទ ឬពីការជាប់ពាក់ព័ន្ធរបស់សហជនជាប់ចោទទៅនឹងការបាញ់ប្រហារនៅរោងចក្រកៅវ៉េនោះទេ។ សាក្សីឃើញផ្ទាល់ភ្នែកជាច្រើននាក់បានរាយការណ៍ថា សហជនជាប់ចោទ បានស្ថិតនៅក្នុងចំណោមនគរបាលដែលមានវត្តមាននៅរោងចក្រម្ខាងទៀតក្នុងតំបន់សេដ្ឋកិច្ចនៅពេលនោះដែរ។ មានការចោទប្រកាន់ក្នុងសំណុំរឿងនេះយ៉ាងច្បាស់លាស់នៅពេលសវនាការជំនុំជម្រះចំពោះមុខសាលាដំបូងខេត្តស្វាយរៀងថា សហជនជាប់ចោទទទួលខុសត្រូវចំពោះការបាញ់ប្រហារលើឈ្មោះ នុត សាខន ខណៈដែលជនជាប់ចោទទទួលខុសត្រូវចំពោះការបាញ់ប្រហារលើជនរងគ្រោះពីរនាក់ផ្សេងទៀត។[12]

ទោះជាយ៉ាងណាក្តី សហជនជាប់ចោទ ពិតជាមានកាំភ្លើងមួយដើមទុកនៅគេហដ្ឋានរបស់ខ្លួន ដែលបានបញ្ជាក់ថា មិត្តជិតស្និទ្ធរបស់គាត់ម្នាក់ជាមន្ត្រីកងរាជអាវុធហត្ថបានឲ្យកាំភ្លើងនោះ។ សហជនជាប់ចោទពុំមានលិខិតអនុញ្ញាតឲ្យកាន់កាប់កាំភ្លើងនោះទេ ហើយបន្ទាប់ពីថ្ងៃបាញ់ប្រហារ គាត់បានត្រូវស្នងការនគបាលស្នើឲ្យយកកាំភ្លើងនោះទៅកាន់ស្នងការដ្ឋាននគរបាល ដែលបន្ទាប់មកកាំភ្លើងនោះក៏ត្រូវបានដកហូតតែម្តង។ ការផ្តន្ទាទោសលើសហជនជាប់ចោទពីបទ "ប្រើប្រាស់អាវុធខុសច្បាប់" គឺពាក់ព័ន្ធទៅនឹងការកាន់កាប់អាវុធដោយពុំមានលិខិតអនុញ្ញាតជាផ្លូវការ ហើយករណីនេះមិនបង្ហាញពីករណីដែលថា ការចោទប្រកាន់គាត់មានអាវុធ ឬប្រើប្រាស់អាវុធ នៅពេលគាត់បំពេញភារកិច្ចនៅតំបន់សេដ្ឋកិច្ចនៅព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ នោះទេ។

---

12 ម៉ៃទិត្យ ធារ៉ា និងខេវិន ប៉ូនី 'ការជំនុំជម្រះលើករណីឈូក បណ្ឌិត បញ្ចប់ដោយព្រះរាជអាជ្ញាធ្វើការចោទប្រកាន់មនុស្សពីរនាក់' កាសែត*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣) អាចរកបានតាម៖<www.phnompenhpost.com/national/bandith-trial-ends-prosecutor-accusing-two។

## ៤. ការចោទប្រកាន់ និងភស្តុតាង

## ការស៊ើបអង្កេត

ជនជាប់ចោទត្រូវបានកំណត់សម្គាល់ភ្លាមៗ ពីក្រសួងមហាផ្ទៃថា ជា "ជនសង្ស័យតែម្នាក់គត់" នៅក្នុងករណីបាញ់ប្រហារនោះ។ មានសេចក្តីរាយការណ៍ថា នគរបាលមានរូបភាពដែលចាប់បានពីកាមេរ៉ាវីដេអូនៅលើអាគាររោងចក្រកៅរ៉េ ដែលបានថតយកសកម្មភាពនៃឧប្បត្តិហេតុនោះ ទោះបីជាមានខ្សែអាត់វីដេអូ ក៏ពុំឃើញខ្សែអាត់នេះត្រូវបានបង្ហាញនៅក្នុងសវនាការជំនុំជម្រះសាលាដំបូង ឬនៅសវនាការសាលាឧទ្ធរណ៍ឡើយ។[13] បើទោះជាមានរបាយការណ៍របស់នគរបាល សេចក្តីថ្លែងការណ៍ពីក្រសួងមហាផ្ទៃ និង សេចក្តីរាយការណ៍ជាច្រើនអំពីករណីបាញ់ប្រហារតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក និងក្រៅស្រុក ដោយសារតែរោងចក្រកៅរ៉េជាប់ទាក់ទិនជាមួយនឹងក្រុមហ៊ុនផលិតស្បែកជើងកីឡាអន្តរជាតិដ៏ធំមួយ គឺ ពូម៉ា អាជ្ញាធរខេត្តស្វាយរៀងពិតជាស្ទាក់ស្ទើរក្នុងចាត់វិធានការលើករណីនេះ ដោយលើកឡើងថា "ខ្វះភាពគួរឲ្យជឿជាក់" នៅក្នុងរបាយការណ៍របស់នគរបាល។[14] យ៉ាងណាក្តី នៅសប្តាហ៍ដំបូងក្នុងខែមីនា ឆ្នាំ២០១២ ជនជាប់ចោទត្រូវបានព្យួរតំណែងជាអភិបាលក្រុងបាវិត ហើយក្រោយមកមានដីកាកោះហៅគាត់ឲ្យចូលខ្លួនទៅកាន់តុលាការដើម្បីសាកសួរ។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង លោក ហ៊ីង ប៊ុនជា បានប្រកាសថា ជនជាប់ចោទត្រូវបានតុលាការសាកសួរ និងបានសារភាពពីការបាញ់ប្រហារទៅលើស្ត្រីបីនាក់ ប៉ុន្តែបានផ្តល់ហេតុផលមួយចំនួនការពារសកម្មភាពរបស់ខ្លួន។ ទោះបីជាមានការសារភាព និងមានបណ្តឹងមកពីជនរងគ្រោះថា មានសមាជិកក្រុមប្រឹក្សាក្រុងបាវិតបានព្យាយាមសូកប៉ាន់ពួកគេមិនឲ្យប្តឹងផ្តល់ ព្រមទាំងបានបង្ខំឲ្យពួកគេលាក់ខ្លួនយ៉ាងណាក្តី ក៏ព្រះរាជអាជ្ញាមិនបានបង្គាប់ឲ្យធ្វើការឃុំខ្លួនបណ្តោះអាសន្នលើជនជាប់ចោទនោះទេ។[15]

សម្ពាធពីសាធារណជនបានជះឥទ្ធិពលយ៉ាងខ្លាំងលើភាពស្ទាក់ស្ទើរយ៉ាងជាក់លាក់របស់ព្រះរាជអាជ្ញាខេត្ត ក្នុងការកសាងសំណុំរឿងប្រឆាំងនឹងជនជាប់ចោទ និងក្រោយមក បទចោទត្រូវបានធ្វើឡើងប្រឆាំងនឹងជនជាប់ចោទនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២។ នៅតែមានក្តីបារម្ភថា សាលាដំបូងខេត្តស្វាយរៀងនឹងទប់ស្កាត់មិនឲ្យជនជាប់ចោទទទួលខុសត្រូវចំពោះការបាញ់ប្រហារនោះ។ ការបារម្ភទាំងនេះ កើតមានតាមរយៈការបដិសេធរបស់តុលាការមិនលើកយកសំណុំរឿងមកជំនុំជម្រះ ព្រោះថាសំណុំរឿងនោះបានបង្វិលទៅមករវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរអស់ជាច្រើនខែ[16] និងតាមរយៈការស្វែងរកជនដៃដល់សប្បនិម្មិតតាមរយៈ

---

[13] ឈូក បណ្ឌិត ត្រូវបានព្យួរតំណែងជាអភិបាលក្រុងបាវិត' កាសែតកោះសន្តិភាព (ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១២) អាចរកបានតាម៖ http://khmerization.blogspot.com/2012/03/chhouk-bandith-suspended-from-position.html ។

[14] ម៉ៃ ទិត្យធារ៉ា និងដេវិត បិយលី 'ជនសង្ស័យក្នុងការបាញ់ប្រហារ គ្មាននរណាក្រៅពីអភិបាលក្រុងបាវិត' កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១២) អាចរកបានតាម៖ www.phnompenhpost.com/national/shooting-suspect-governor-no-more ។

[15] ឆៃ ចាន់នីដា និងដេវិត បិយលី 'អ្នកបាញ់កម្មការិនីរោងចក្រ "សារភាព' កាសែតភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១២) អាចរកបានតាម៖ www.phnompenhpost.com/national/factory-shooter-%e2%80%98confesses%e2%80%99 ។

[16] ម៉ៃ ទិត្យធារ៉ា 'ការកោះហៅនៅតែមានការព្យួរក្នុងករណីបាញ់ប្រហារនៅក្នុងរោងចក្រពូម៉ា' កាសែត*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២) អាចរកបានតាម៖<www.phnompenhpost.com/national/summons-still-pending-puma-shooting>

សេចក្តីសម្រេចរបស់ខ្លួនក្នុងការចោទប្រកាន់សហជនជាប់ចោទ។ នៅក្នុងដំណាក់កាលនេះហើយ ដែលទាំងជនរងគ្រោះ និងជនជាប់ចោទត្រូវបានតុលាការកោះហៅជាថ្មីដើម្បីមក "បំភ្លឺ" ភស្តុតាងរបស់ខ្លួន ដែលជនជាប់ចោទកែប្រែការសារភាពរបស់ខ្លួនកាលពីដំបូង និងបានឆ្លើយបំភ្លឺថា ខ្លួនគ្រាន់តែបានដក និងភ្ជង់កាំភ្លើងឡើងទៅលើ ដោយបដិសេធថា មិនបានបាញ់នោះទេ។

នៅក្នុងខែសីហា ឆ្នាំ២០១២ សហជនជាប់ចោទ ត្រូវបានតុលាការចោទយ៉ាងស្ងាត់ៗពីបទ "*បង្ករបួសស្នាមដោយអចេតនា*" ទៅលើជនរងគ្រោះទាំងបីនាក់ ហើយនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ការបារម្ភដែលថាសាលាដំបូងខេត្តមិនបានធ្វើការស៊ើបអង្កេតពីករណីបាញ់ប្រហារនោះឲ្យសុក្រឹត ត្រូវបានស្តែងឡើងនៅពេលមានការទម្លាក់បទចោទប្រកាន់លើជនជាប់ចោទពីសំណាក់តុលាការ។ ពុំមានសេចក្តីពន្យល់ណាមួយត្រូវបានផ្តល់ជូនចំពោះសេចក្តីសម្រេចរបស់តុលាការក្នុងការទម្លាក់ចោលបទចោទប្រកាន់លើជនជាប់ចោទ ឬការកសាងសំណុំរឿងប្រឆាំងនឹងសហជនជនជាប់ចោទឡើយ។[17]

បន្ទាប់មកមានការជំទាស់យ៉ាងខ្លាំងជាសាធារណៈនៅតាមបណ្តាញផ្សព្វផ្សាយព័ត៌មាន និងពីសង្គមស៊ីវិល[18] សាលាឧទ្ធរណ៍បានសម្រេចទទួលយកសំណុំរឿងរបស់ជនជាប់ចោទពីសាលាដំបូងខេត្តស្វាយរៀងនៅថ្ងៃទី០២ ខែមករា ឆ្នាំ២០១៣ ដែលជាការបើកផ្លូវឲ្យមានការស៊ើបអង្កេតឡើងវិញ។[19] នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ពីរថ្ងៃបន្ទាប់ពីសវនាការបិទទ្វារពិនិត្យលើភស្តុតាង ដែលជនជាប់ចោទបានចូលរួមផងនោះ[20] អង្គស៊ើបសួរនៃសាលាឧទ្ធរណ៍បានចោទប្រកាន់ជនជាប់ចោទជាថ្មីម្តងទៀត ដូចគ្នាទៅនឹងបទចោទរបស់សាលាដំបូងខេត្តកាលពីលើកមុន។[21] បន្ទាប់មក សំណុំរឿងនោះត្រូវបានបង្វិលត្រឡប់ទៅសាលាដំបូងខេត្តស្វាយរៀងឲ្យបើកសវនាការជំនុំជម្រះវិញ។ តែយ៉ាងណាក្តី នៅតែពុំមានការបង្គាប់ឲ្យឃុំខ្លួនជាបណ្តោះអាសន្នលើជនជាប់ចោទនោះទេ។

## ការជំនុំជម្រះនៅសាលាដំបូង

បើទោះជាមានសេចក្តីសម្រេចពីសាលាឧទ្ធរណ៍យ៉ាងណាក្តី ក៏សាលាដំបូងខេត្តនៅតែពន្យារពេលក្នុងការលើកយកសំណុំរឿងនោះមកជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទដដែល។ [22] កាលបរិច្ឆេទជំនុំជម្រះដំបូងឡើយត្រូវបានកំណត់នៅខែឧសភា ឆ្នាំ២០១៣ ប៉ុន្តែ ជនជាប់ចោទនៅតែបានលាក់ខ្លួននៅឡើយ ហើយនៅ

---

17 ម៉ៃ ទិត្យធារ៉ា និងអេប៊ី សៀហ្ស 'ឈូក បណ្ឌិត ត្រូវបានតុលាការទំលាក់ការចោទប្រកាន់' កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២)។

18 មានប្រភពដូចខាងលើ

19 ជាង សុខា ' ឈូក បណ្ឌិត ប្តឹងទៅសាលាឧទ្ធរណ៍' កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៣)។

20 មានប្រភពដូចខាងលើ

21 អង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស ("លីកាដូ") ' សាលាឧទ្ធរណ៍ភ្ជាប់បទចោទតិចតួចលើ ឈូក បណ្ឌិត ដីការបង្គាប់ឲ្យជំនុំជម្រះ'(ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣) អាចរកបានតាម៖ <www.licadho-cambodia.org/flashnews.php?perm=15

22 ម៉ៃ ទិត្យធារ៉ា 'លើកទីពីរក្នុងសំណុំរឿង ឈូក បណ្ឌិត ជាប់គាំងនៅខែឧសភា កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣) អាចរកបានតាម៖ <www.phnompenhpost.com/national/round-2-bandith-case-locked-may ៀ

ពេលកាលបរិច្ឆេទដែលបានកំណត់នៅខែឧសភា មកដល់ មេធាវីការពារក្តីជនជាប់ចោទ បានដាក់ពាក្យបញ្ជាក់ប្រាប់តុលាការថា កូនក្តីរបស់ខ្លួនជាប់បំពេញបេសកម្ម និងស្នើឲ្យបន្តដំណើរការនីតិវិធីជំនុំជម្រះដោយ*កំបាំងមុខ* ជាលទ្ធផល ចៅក្រមសាលាដំបូងខេត្ត លោក លាង សួគ៌ បានអនុញ្ញាតឲ្យលើកពេលសវនាការជំនុំជម្រះ។[23]

នៅទីបំផុត សវនាការជំនុំជម្រះលើជនជាប់ចោទ និងសហជនជាប់ចោទ ត្រូវបានធ្វើឡើងនៅសាលាដំបូងខេត្តស្វាយរៀង នៅចន្លោះពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣។ ជនជាប់ចោទនៅតែអវត្តមាន ប៉ុន្តែមានមេធាវីការពារ។ មេធាវីការពារក្តីជនជាប់ចោទ បានលើកឡើងថា ជនជាប់ចោទបានសម្រេចមិនចូលរួមសវនាការដោយសារតែបញ្ហាបច្ចេកទេសនៅក្នុងការទទួលដីកាកោះ។ សាក្សីជាច្រើននាក់មានវត្តមាន រួមមាន៖ សាក្សីដាក់បន្ទុកលើជនជាប់ចោទចំនួន ១៩ នាក់ និងសាក្សីដោះបន្ទុក ៣ នាក់ ជាមួយនឹងសាក្សីដាក់បន្ទុកលើសហជនជាប់ចោទចំនួន ៨ នាក់បន្ថែមទៀត និងសាក្សីដោះបន្ទុកចំនួន ២៥នាក់។

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ សាលាដំបូងខេត្ត បានប្រកាសសាលក្រមរបស់ខ្លួន។ ជនជាប់ចោទត្រូវបានតុលាការចោទប្រកាន់ពីបទ *"បង្ករបួសស្នាមដោយអចេតនា"* ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១៨ ខែ និងបង្គាប់ឲ្យសងសំណងជំងឺចិត្តសរុបចំនួន ៣៨ លានរៀល ជូនដល់ជនរងគ្រោះទាំងបីនាក់។ សហជនជាប់ចោទត្រូវបានតុលាការលើកលែងការចោទពីបទ *"បង្ករបួសស្នាមដោយអចេតនា"* ប៉ុន្តែមានពិរុទ្ធពីបទ *"ប្រើប្រាស់អាវុធខុសច្បាប់"* ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៦ ខែ និងពិន័យជាប្រាក់ចំនួន ១លានរៀល។ ចុងក្រោយ សាលាដំបូងខេត្តបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទ។[24]

បន្ទាប់ពីការផ្តន្ទាទោស មានព័ត៌មានលេចឮថា ជនជាប់ចោទកំពុងលាក់ខ្លួននៅខេត្តរតនៈគិរី ឬខេត្តមណ្ឌលគិរី។[25] មានការព្រួយបារម្ភជាខ្លាំងត្រូវបានលើកឡើងអំពីឆន្ទៈរបស់អាជ្ញាធរក្នុងការតាមចាប់ខ្លួនជនជាប់ចោទ ហើយចង់ឃើញជនជាប់ចោទទទួលទោសដែលតុលាការបានកំណត់ ឬផ្តល់សំណងដ៏ត្រឹមត្រូវដល់ជនរងគ្រោះ។

## កស្តុតាងនៅពេលជំនុំជម្រះរបស់សាលាដំបូង

---

23 ម៉ៃ ទិត្យធារ៉ា ' ឈូក បណ្ឌិត ពុំបានបង្ហាញខ្លួននៅក្នុងការជំនុំជម្រះក្តី' កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣) អាចរកបានតាម៖ <www.phnompenhpost.com/national/bandith-no-shows-trial>.

24 សុជីវី សាមៀន យុន និង ចូហ្សេ្វ លីប៉េស ' អតីតអភិបាលក្រុងបាវិតទទួលទោសជាប់ពន្ធនាគាររយៈពេល១៨ខែក្នុងករណីបាញ់ប្រហារលើកម្មការិនីរោងចក្រ' វិទ្យុអាស៊ីសេរី (ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣) អាចរកបានតាម៖ www.rfa.org/english/news/cambodia/verdict-06252013165812.html>។

25 វ៉ាន់ វិជ្ជា សាមៀន យុន និងវ៉ាឈេល វ៉ាន់ដេនប្រីង 'ជនជាប់ចោទជាអតីតអភិបាលអភិបាលកំពុងលាក់ខ្លួន' *វិទ្យុអាស៊ីសេរី* (ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣) អាចរកបានតាម៖ www.rfa.org/english/news/cambodia/chhouk-bandith-07032013190621.html> ។

សវនាការជំនុំជម្រះបានផ្តោតសំខាន់តែទៅលើការស្វែងរកជនដែលបានបាញ់កាំភ្លើង ដែលបណ្តាលឲ្យជនរងគ្រោះរបួស។ ភស្តុតាងជាច្រើនស្តីពីសកម្មភាពរបស់ជនជាប់ចោទ គឺពិតជាគ្មានអ្វីដែលត្រូវជំទាស់នោះទេ ដែលនៅសល់បញ្ហាគន្លឹះមួយទៀតត្រង់ថាតើគាត់ពិតជាបានកេះកៃកាំភ្លើង ដែលគាត់បានដកចេញពីចង្កេះ និងតម្រង់ទៅកម្មកររោងចក្រកៅស៊ូឬយ៉ាងណា។

មេធាវីការពារក្តីជនជាប់ចោទ បានពឹងផ្អែកលើចម្លើយរបស់ជនជាប់ចោទ ដែលបានផ្តល់ជូនទៅចៅក្រមស៊ើបសួរកាលពីឆ្នាំមុនពីករណី ដែលនៅក្នុងចម្លើយនោះ ជនជាប់ចោទបានទទួលស្គាល់ថាខ្លួនបានដកកាំភ្លើង ហើយបានភ្ជង់ទៅលើ ប៉ុន្តែបានបដិសេធពុំបានបាញ់នោះទេ។ កំណត់ហេតុចម្លើយរបស់ជនជាប់ចោទបានបញ្ជាក់បន្ថែមទៀតថា ខ្លួនមិនបានឮស្នូរផ្ទុះអាវុធណាមួយនោះទេ មុនពេលគាត់រត់ចេញ ហើយគាត់ក៏មិនបានដឹងថាមានអ្នករងរបួសនោះដែរ។ ជារឿងមិនគួរឲ្យជឿដែលថា ជនជាប់ចោទមិនអាចចងចាំបានថាកាំភ្លើងនោះទៅដល់កន្លែងណា បន្ទាប់ពីរូបគាត់បានគៀសខ្លួនចេញ ហើយក៏មិនដឹងថាហេតុអ្វីបានជាគាត់ចាំបាច់ត្រូវគេចខ្លួនពីកន្លែងកើតហេតុនោះទេ។ ជនជាប់ចោទបាននិយាយថា កាំភ្លើងនោះមិនអាចបាញ់បានទេ ដោយសារតែមានបញ្ហាបច្ចេកទេស ដូច្នេះហើយបានជាគាត់ប្រគល់កាំភ្លើងនោះឲ្យទៅអ្នកផ្សេងទៀត (គាត់ចាំមិនបានថាជាអ្នកណានោះទេ) ព្រមទាំងបានបញ្ជាក់ថា គាត់បានត្រឹមតែដកកាំភ្លើងឡើងប៉ុណ្ណោះ ពីព្រោះមិនចង់ឲ្យកម្មករចោលដុំថ្មដាក់គាត់។

អវត្តមានដោយគ្រោងទុកជាមុនរបស់ជនជាប់ចោទ មានន័យថា ជនជាប់ចោទមិនចាំបាច់ត្រូវប្រឈមនឹងការសួរនាំខណៈដែលគាត់មិនសូវមានការចងចាំថាកាំភ្លើងនោះទៅឯណា ឬមានហេតុផលត្រឹមត្រូវដែលធ្វើឲ្យគាត់សម្រេចចិត្តរត់គេច នៅពេលដែលគាត់បានធ្វើដូច្នោះ បើតាមពាក្យសម្តីគាត់ថា គ្មានការផ្ទុះអាវុធ និងគ្មាននរណាម្នាក់រងរបួសនោះទេ។ អវត្តមាននៃកាំភ្លើងនោះក្រោយព្រឹត្តិការណ៍គឺមានសារៈសំខាន់ ដោយសារតែអាវុធនេះ អាចនឹងក្លាយជាវត្ថុតាងដ៏សំខាន់នៅក្នុងសំណុំរឿងនេះ ដែលជាការបង្ហាញឲ្យបានច្បាស់លាស់ថា តើជនជាប់ចោទពិតជាបានបាញ់កាំភ្លើង ឬក៏អត់។ ការបាត់បង់ការចងចាំពីទីកន្លែងដែលអាវុធនោះត្រូវបានប្រគល់អោយទុក បន្ទាប់ពីគាត់គេចខ្លួនគឺប្រហែលជាកាន់តែស៊ីសង្វាក់គ្នាជាមួយនឹងការគិតទុកជាមុនពីការបោះចោលកាំភ្លើងដែលបានប្រើប្រាស់ក្នុងបទល្មើសនោះហើយ និងជាការព្យាយាមលាក់បំបាំងភស្តុតាង។ ជនជាប់ចោទក៏មិនចាំបាច់ត្រូវប្រឈមនឹងការសួរដេញដោលលើភាពផ្ទុយគ្នារវាងការសារភាពរបស់គាត់ចំពោះការបាញ់ប្រហារលើជនរងគ្រោះដែលបានលើកឡើងទៅកាន់ព្រះរាជអាជ្ញាខេត្តកាលពីខែមីនា ឆ្នាំ២០១២ និងការបដិសេធជាបន្តបន្ទាប់ពីការបាញ់ប្រហារណាមួយដែលបានលើកឡើងទៅកាន់ចៅក្រមស៊ើបសួរ។

កំណត់ហេតុដែលបានមកពីសាក្សីឃើញផ្ទាល់ភ្នែក បានផ្តល់នូវភស្តុតាងគួរឲ្យជឿជាក់ពីការបាញ់ប្រហារនោះថា ជាអំពើគិតទុកជាមុនរបស់ជនជាប់ចោទ។ តុលាការបានស្តាប់សក្ខីកម្ម និងបានទទួលស្គាល់ថា

ជនរងគ្រោះពិតជាបានស្នាក់នៅព្យាបាលនៅមន្ទីរពេទ្យអស់រយៈពេលជាច្រើនសប្តាហ៍[26] ដោយសាររងរបួសដោយការបាញ់ប្រហារនោះ ហើយបើយោងតាមការផ្តល់សក្ខីកម្មរបស់សាក្សីចំនួន ២៥ នាក់នៅចំពោះមុខតុលាការ មានសាក្សីចំនួន ៣ នាក់ក្នុងចំណោមសាក្សីទាំងនោះបន្ទាប់មកបានផ្តល់សក្ខីកម្មផ្ទាល់មាត់នៅសវនាការជំនុំជម្រះសាលាដំបូង ដែលថា មានតែជនជាប់ចោទម្នាក់ប៉ុណ្ណោះដែលបានកាន់កាំភ្លើងឡើងនៅតំបន់ជិតរោងចក្រកៅវ៉េ នៅចំពេលដែលជនរងគ្រោះទាំងនោះត្រូវរបួស។

តុលាការបានលើកឡើងថា បន្ទាប់ពីត្រូវបានមន្ត្រីនគរបាល ទាក់ទងឲ្យមកបំពេញភារកិច្ចនៅរោងចក្រកៅវ៉េ ជនជាប់ចោទបានចេញពីគេហដ្ឋានរបស់ខ្លួនដោយមានអាវុធមកជាមួយផង។ នៅពេលមកដល់រោងចក្រកៅវ៉េ ជនជាប់ចោទក៏បានយកអាវុធនៅក្នុងរថយន្តរបស់ខ្លួន ហើយបាននិយាយជាមួយនឹងនគរបាលនៅចក្រទ្វារខាងក្រោយ មុនពេលចូលទៅក្នុងបរិវេណរោងចក្រ និងបានស្រែកដាក់កម្មករដែលចោលដុំថ្មដាក់កាមេរ៉ាដែលស្ថិតនៅក្នុងរោងចក្រកៅវ៉េ ដោយជនជាប់ចោទមានកាំភ្លើងជាប់នឹងខ្លួននៅឡើយ។ ជនជាប់ចោទដែលខ្លួនជាមន្ត្រីជាន់ខ្ពស់ម្នាក់នៅថ្នាក់មូលដ្ឋានរបស់រដ្ឋាភិបាល គួរតែបានដឹងពីបទបញ្ញាមិនអនុញ្ញាតឲ្យនគរបាលប្រើអាវុធគ្រឿងផ្ទុះដែលប៉ះពាល់ដល់អាយុជីវិតប្រឆាំងនឹងកូដករឡើយ។ ស្ថានភាពនៅពេលនោះ គឺជនជាប់ចោទកាន់អាវុធដោយខ្លួនឯងដោយគ្រោងទុកជាមុន ហើយបានចូលទៅកាន់បរិវេណរោងចក្រដែលមានកម្លាំងនគរបាលនៅការពារអាយុជីវិត និងទ្រព្យសម្បត្តិរួចទៅហើយនោះ ជនជាប់ចោទបានដើរសំដៅទៅក្រុមកម្មករ និងបានស្រែកដាក់កម្មករ ហើយក្រោយមកបានសម្រេចប្រើអាវុធរបស់ខ្លួនបាញ់លើកម្មករតែម្តង។

សាក្សីមួយចំនួនបានផ្តល់សក្ខីកម្មថា ជនជាប់ចោទបានលើកកាំភ្លើង និងតម្រង់ទៅរកក្រុមកម្មករនៅចំពេលដែលជនរងគ្រោះកំពុងតែឈរនៅមួយចំហៀងច្រកដែលមានបញ្ហា ហើយជនជាប់ចោទបានបាញ់ពីរទៅបីដង មុនពេលកាំភ្លើងនោះគាំងបាញ់លែងចេញគ្រាប់ ហើយជនជាប់ចោទមិនអាចបាញ់ទៅលើក្រុមកម្មករទាំងនោះបានទៀតនោះទេ។ ភស្តុតាងបានមកពីមន្ត្រីនគរបាលនៅកន្លែងកើតហេតុគឺថា ភ្លាមៗនៅពេលដែលកាំភ្លើងនោះគាំង ជនជាប់ចោទបានប្រគល់វាទៅឲ្យសហការីរបស់ខ្លួន ឈ្មោះ ជា ស៊ីណា ដើម្បីជួយដោះសោរដែលនាំឲ្យគាំង។ បន្ទាប់មក ជនជាប់ចោទបានរត់ចេញពីរោងចក្រកើតហេតុ។

ចំពោះសហជនជាប់ចោទឯណោះវិញ សាលាដំបូងខេត្តស្វាយរៀងមានភស្តុតាងទាំងអស់ ដែលបញ្ជាក់ថា ជនជាប់ចោទ គឺជាមនុស្សតែម្នាក់គត់ដែលទទួលខុសត្រូវចំពោះការបាញ់ប្រហារ និងបន្ថែមលើនេះទៀត មានភស្តុតាងជាសាក្សីមិនតិចជាង ៨ នាក់ទេ ដែលបានផ្តល់សក្ខីកម្មថា សហជនជាប់ចោទបានធ្វើត្រួតត្រានៅរោងចក្រយីងម៉េកឃើ និងហ្សេក្ខ នៅផ្នែកម្ខាងទៀតនៃតំបន់សេដ្ឋកិច្ចនៅពេលមានការបាញ់ប្រហារ។

[26] ប៊ុន ចិន្តា នៅមិនទាន់បានជាសះស្បើយពីរបួសលើដើមទ្រូងនៅមន្ទីរពេទ្យជិតពីសប្តាហ៍បន្ទាប់ពីការវាយប្រហារ សុ ជីវី សាមឿន យុន និងចូហ្សេហ្វ លីប៉េស ' កម្មករប្តឹងពីករណីបាញ់ប្រហារ' វិទ្យុអាស៊ីសេរី (ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៣) អាចរកបានតាមៈ <www.rfa.org/english/news/cambodia/lawsuit-03132012170105.html>

សាក្សីម្នាក់ដែលមានបំណងផ្ដល់សក្ខីកម្ម ដើម្បីបញ្ជាក់ពីបទឧក្រិដ្ឋនៃការបាញ់ប្រហាររបស់សហជនជាប់ចោទបានផ្លាស់ប្ដូរចម្លើយរបស់ខ្លួនមិនតិចជាងបីដងនោះទេ។ ពីដំបូង សាក្សីនោះបានអះអាងក្នុងសេចក្ដីថ្លែងការណ៍របស់ខ្លួនប្រាប់នគរបាលថា ខ្លួនគ្រាន់តែបានឃើញសហជនជាប់ចោទដើរចេញពីច្រកទ្វារខាងក្រោយរោងចក្រកៅស៊ូតែប៉ុណ្ណោះ។ យ៉ាងណាក្ដី នៅក្នុងសេចក្ដីថ្លែងការណ៍ក្រោយៗមកទៀតទៅកាន់ចៅក្រមស៊ើបសួរ និងតំណាងអយ្យការ សាក្សីដដែលនេះបានអះអាងថា បានឃើញសហជនជាប់ចោទបាញ់កាំភ្លើងនៅពេលផ្សេងៗគ្នា។

ដោយពិនិត្យពិចារណាលើកំណត់ហេតុដែលមិនគួរឲ្យជឿជាក់ និងផ្ទុយនឹងចម្លើយរបស់ខ្លួនឯងរបស់សាក្សីម្នាក់ដែលថា សហជនជាប់ចោទបានបាញ់ទៅលើកម្មកររោងចក្រកៅស៊ូ នេះជារឿងដ៏ពិបាកយល់អំពីហេតុផលដែលនាំឲ្យសហជនជាប់ចោទធ្លាប់ត្រូវបានតុលាការចោទពីបទ "*បង្ករបួសស្នាមដោយអចេតនា*"។ ករណីនេះរឹតតែនាំឲ្យពិបាកយល់ពីហេតុផល ដែលនាំឲ្យសហជនជាប់ចោទជាប់ពាក់ព័ន្ធ នៅពេលដែលមានភស្ដុតាងជាច្រើននៅតំណាងអយ្យការ និងចៅក្រមស៊ើបសួរដែលបង្ហាញថា មានតែជនជាប់ចោទម្នាក់ប៉ុណ្ណោះដែលទទួលខុសត្រូវចំពោះការបាញ់ប្រហារនោះ ព្រមទាំងថែមទាំងមានភស្ដុតាងជាច្រើនទៀតបង្ហាញថា សហជនជាប់ចោទស្ថិតនៅរោងចក្រផ្សេងនៅក្នុងតំបន់សេដ្ឋកិច្ចនៅពេលជនរងគ្រោះបានរងរបួស។ ហេតុដូច្នេះ ជាការទំនងណាស់ដែលថា ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង និងតុលាការ បានស្វះស្វែងរកជនដៃដល់សប្បនិម្មិតដើម្បីទទួលខុសត្រូវលើការបាញ់ប្រហារ នៅពេលដែលខ្លួនប្រឈមនឹងស្ថានភាពមួយដែលមានមន្ត្រីជាន់ខ្ពស់ជាប់ពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុនោះ ដែលបានធ្វើឲ្យចាប់អារម្មណ៍ពីបណ្ដាញផ្សព្វផ្សាយព័ត៌មានជាច្រើន ព្រមទាំងមានការរិះគន់ពីសង្គមស៊ីវិល និងជាលទ្ធផលនៅពេលដែលអាជ្ញាធរមូលដ្ឋានត្រូវបានគេមើលឃើញថាបានចាត់វិធានការជាក់ស្ដែង។ ការស្វែងរកអ្នកទទួលកំហុសសប្បនិម្មិតនេះកាន់តែទំនងថែមទៀត នៅពេលឃើញមានការចោទប្រកាន់លើសហជនជាប់ចោទភ្លាមៗ បន្ទាប់ពីមានការទម្លាក់បទចោទប្រកាន់ទាំងអស់លើជនជាប់ចោទ។ ចំពោះព្រះរាជអាជ្ញាដែលមានវត្តមាននៅសវនាការជំនុំជម្រះសាលាដំបូងក្នុងការផ្ដល់សេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា សហជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះការបាញ់ប្រហារលើជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះទាំងអស់ គឺជាការបង្ហាញពីការព្យាយាមរបស់អាជ្ញាធរខេត្តបានត្រៀមរៀបចំក្នុងការសម្រាលដល់ការបន្ទុកលើជនជាប់ចោទ។

## ការវិភាគលើបទចោទប្រកាន់

ដោយពិនិត្យពិចារណាលើភស្ដុតាងនៃសកម្មភាពគ្រោងទុកជាមុនរបស់ជនជាប់ចោទក្នុងអំឡុងពេលនៃការបាញ់ប្រហារ អត្ថបទវិភាគផ្លូវច្បាប់នេះ ធ្វើសេចក្ដីសន្និដ្ឋានថា ការចោទប្រកាន់ និងចុងក្រោយការផ្ដន្ទាទោសពីបទ "*បង្ករបួសស្នាមដោយអចេតនា*" (មាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ) នៅក្នុងសំណុំរឿងរបស់ជនជាប់ចោទគឺ មិនទាន់គ្រប់គ្រាន់ និងមិនត្រឹមត្រូវតាមច្បាប់នៅឡើយទេ។ ភស្ដុតាងមាននៅព្រះរាជអាជ្ញាអមសាលាដំបូងខេត្ត និងនៅចៅក្រមស៊ើបសួរបាន បញ្ជាក់យ៉ាងហោចណាស់ ករណីនេះជា "*ហិង្សាដោយចេតនា*"

*តាំងពីដំបូងមកម្លេះ* (ដែលផ្ទុយទៅនឹងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ដោយមានស្ថានទម្ងន់ទោសតាមរយៈការប្រើប្រាស់អាវុធអនុលោមតាមមាត្រា ២១៨(២) នៃក្រមព្រហ្មទណ្ឌ) និងអាចនឹងឈានដល់ការចោទប្រកាន់រហូតដល់បទ "ប៉ុនប៉ងមនុស្សឃាត" (មាត្រា២៧ និងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ)។

មាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ ផ្តល់អត្ថន័យនៃបទល្មើស *"បង្ករបួសស្នាមដោយអចេតនា" ថាជា "អំពើដែលបណ្តាលឲ្យមានរបួសដល់អ្នកដទៃដោយៈ*

*១- ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ដែលបង្កឲ្យមានអសមត្ថភាពក្នុងការធ្វើការងារស្មើ ឬលើសពី ៨ (ប្រាំបី) ថ្ងៃ។*

*២- ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ"។*

នៅក្នុងសវនាការជំនុំជម្រះសាលាដំបូងខេត្ត សកម្មភាពនានារបស់ជនជាប់ចោទ និងសហជនជាប់ចោទ ត្រូវបានពិនិត្យមើលតែទៅលើអ្វីដែលបានរៀបរាប់នៅក្នុងផ្នែកទី១ខាងលើតែប៉ុណ្ណោះ។ ដោយគ្មានមន្ទិលសង្ស័យ កម្រិតនៃការរងរបួសរបស់ជនរងគ្រោះ គឺមានលក្ខណៈគ្រប់គ្រាន់ក្នុងការយល់ឃើញថាបំពេញតាមលក្ខខណ្ឌនៃមាត្រា ២៣៦ (១)។ សាលាដំបូងខេត្តបានធ្វើសេចក្តីសន្និដ្ឋានថា ក្រុមប្រឹក្សាជំនុំជម្រះប្រាកដណាស់ថា ជនជាប់ចោទគឺជាអ្នកដែលបានបាញ់លើជនរងគ្រោះទាំងបីនាក់។ បញ្ហាដែលសាលាដំបូងខេត្ត (និងសាលាឧទ្ធរណ៍) ខកខានពុំបានដោះស្រាយថាតើកម្រិតនៃការចោទប្រកាន់នោះបានឆ្លុះបញ្ចាំងគ្រប់គ្រាន់ពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទនោះ ឬយ៉ាងណា។

ដូច្នោះហើយ បញ្ហាពិតប្រាកដរបស់ការវិភាគផ្លូវច្បាប់នេះ គឺៈ តើអ្វីទៅជាធាតុផ្សំនៃចេតនារបស់ជនជាប់ចោទ (ធាតុអត្តនោម័តិ) នៅពេលបាញ់ប្រហារនោះ? តើជនជាប់ចោទបានធ្វើសកម្មភាពដោយគ្រាន់តែធ្វេសប្រហែស មិនប្រុងប្រយ័ត្ន ឬខ្ជីខ្ជា? ឬក៏ តើតុលាការមានសមត្ថកិច្ច និងមិនលម្អៀង បានអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវតាមភស្តុតាងដែលបានបង្ហាញនៅសវនាការជំនុំជម្រះសាលាដំបូង ក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកតាមបទដ្ឋានព្រហ្មទណ្ឌជាចាំបាច់ ដែលថា សកម្មភាពរបស់ជនជាប់ចោទ បានប្រព្រឹត្តដោយចេតនា ឬដោយឆន្ទៈ?

ហេតុដូច្នេះ បើតាមកំណត់ហេតុនៃចម្លើយផ្ទាល់ខ្លួនរបស់ជនជាប់ចោទ នេះមិនមែនជាស្ថានភាពដែលជនជាប់ចោទបានអះអាងថា ខ្លួនបានកំពុងតែមានការប្រទាញប្រទង់កាំភ្លើង ដែលខ្លួនកាន់ ដូច្នេះ វាក៏បានផ្ទុះដោយចៃដន្យ ឬខ្លួនមានការយល់ខុសពីស្ថានការណ៍នៅពេលនោះដែលឈានដល់ការប្រើប្រាស់កាំភ្លើង ឬក៏ថាខ្លួនមិនបានដឹងពីវត្តមានរបស់កម្មកររោងចក្រនៅកន្លែងជិតនោះទេ។ ជនជាប់ចោទបានបដិសេធថាមិនបានបាញ់កាំភ្លើងទាល់តែសោះ ហើយបានព្យាយាមទម្លាក់កំហុសដាក់អ្នកដទៃចំពោះការបាញ់ប្រហារនោះ ដោយថ្លែងថា ជនរងគ្រោះច្បាស់ជារងរបួសនៅពេលមានចលាចលដែលកើតឡើងបន្ទាប់ពីមានការរត់គេចខ្លួនរបស់គាត់ នៅពេលនោះគាត់បាននិយាយថាមានការផ្ទុះអាវុធ។ ដូច្នេះ នៅក្នុងវិសាលភាពនេះ ការធ្វេសប្រហែស និង

ការមិនប្រុងប្រយ័ត្ន គួរតែត្រូវបានមិនសមហេតុផលភ្លាមៗ។ នេះជាបញ្ហាដ៏សាមញ្ញនៃអង្គហេតុ៖ តើជនជាប់ចោទបានបាញ់ជនរងគ្រោះ ឬទេ?

ក៏មិនមែនជារឿងដែលជនជាប់ចោទបានអះអាងថា ខ្លួនបានបាញ់តម្រង់ទៅកាន់ក្រុមកម្មករ ដែលយល់ឃើញមិនត្រឹមត្រូវថា ខ្លួនធ្វើសកម្មភាពក្នុងន័យការពារខ្លួនស្របតាមមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌ។[27] ក្រៅពីការបដិសេធទាំងស្រុងពីការបាញ់កាំភ្លើង ជនជាប់ចោទបានចូលខ្លួនឆ្លើយបំភ្លឺតាមកំណត់ហេតុនៃចម្លើយរបស់ខ្លួនទៅកាន់ចៅក្រមស៊ើបសួរថា គាត់បានដឹងថាកាំភ្លើងនោះគាំង ហើយគាត់គ្រាន់តែប្រើវាដើម្បីជាការសម្លែងក្នុងគោលបំណងរារាំងកម្មករមិនឲ្យចោលដុំថ្មដាក់ខ្លួនតែប៉ុណ្ណោះ។ ជនជាប់ចោទមិនបានលើកឡើងថាការបាញ់កាំភ្លើងអាចនឹងមានសមាមាត្រទៅនឹងស្ថានភាពដែលខ្លួនកំពុងតែប្រឈម ឬថាខ្លួនត្រូវបានបង្ខំចិត្តបាញ់កាំភ្លើងដើម្បីការពារខ្លួន ការពារជនដទៃ ឬការពារទ្រព្យសម្បត្តិនោះឡើយ។ ការបង្ហាញថា សកម្មភាពរបស់ជនជាប់ចោទអាចត្រឹមត្រូវតាមផ្លូវច្បាប់ ដែលជាការឆ្លើយតបទៅនឹងសកម្មភាពរបស់កម្មកររោងចក្រកៅស៊ូ ត្រូវបានបដិសេធចោលដោយអង្គហេតុដែលបានលើកឡើងនៅសវនាការជំនុំជម្រះសាលាដំបូង។ កម្មករភាគច្រើនត្រូវបានគេនិយាយថា បានកំពុងតែព្យាយាមកម្ទេចកាមេរ៉ា ស៊ីស៊ីធីវី ចំនួនបី ហើយមានវត្តមាននគរបាលដែលជនជាប់ចោទបាននិយាយទៅកាន់នៅពេលខ្លួនដើរចូលទៅ និងជាអ្នកដែលត្រូវបានបញ្ជូនទៅតំបន់សេដ្ឋកិច្ចដើម្បីដោះស្រាយនូវចលាចលនៅរោងចក្រ ព្រមទាំងមានភស្តុតាងដែលថា ជនជាប់ចោទបានប្រឈមពាក្យសម្តីជាមួយនឹងកម្មករ មុនពេលបែរទៅរកកម្មករ និងបាញ់ប្រហារលើពួកគេ។ ក្នុងន័យនេះ ការប្រើប្រាស់អាវុធគ្មានយុត្តិកម្មនោះទេ។ ការប្រើប្រាស់កាំភ្លើងនេះពុំសមាមាត្រទៅនឹងសកម្មភាពកម្ទេចកាមេរ៉ាដែលកូដករបង្កឡើង ហើយជនជាប់ចោទមិនត្រូវបានបង្ខំឲ្យធ្វើសកម្មភាព ខណៈដែលខ្លួនបានទៅពិនិត្យពិច័យ និងបានប្រឈមគ្នាជាមួយកម្មករ ព្រមទាំងនគរបាលមានវត្តមាននៅទីនោះដើម្បីការពារអាយុជីវិតមនុស្ស និងទ្រព្យសម្បត្តិនានានៅទីនោះ។

ប្រសិនជាភស្តុតាងរបស់សាក្សីជាច្រើននាក់ត្រូវបានទទួលយកដោយតុលាការ ថាមានលក្ខណៈគ្រប់គ្រាន់ក្នុងការធានាដល់បទដ្ឋានព្រហ្មទណ្ឌដែលថា ជនជាប់ចោទពិតជាបានបាញ់កាំភ្លើង និងបានបង្ករបួសស្នាមដល់ជនរងគ្រោះ វាជារឿងលំបាកក្នុងការទទួលយកនូវមូលហេតុ ដែលថាតុលាការបានឈានដល់សេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួនថា សកម្មភាពរបស់ជនជាប់ចោទ មិនមែនជាអំពើគិតទុកជាមុននោះទេ។

ជាបញ្ហាអង្គច្បាប់ នេះជាការព្យាករណ៍ទុកជាមុនដ៏សមហេតុផល និងជាការប្រាកដណាស់ចំពោះជនជាប់ចោទដែលថា ការបាញ់កាំភ្លើងដោយគ្រោងទុកជាមុន និងម្តងហើយម្តងទៀតតម្រង់ចូលទៅកាន់ក្រុមកម្មករនឹងបណ្តាលឲ្យមានមនុស្សស្លាប់ ឬយ៉ាងហោចណាស់ក៏បណ្តាលឲ្យមានអ្នករងរបួសធ្ងន់ដែរ។ សេចក្តី

---

[27] មាត្រា ៣៣ "បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ" ការការពារស្របច្បាប់ត្រូវមានលក្ខខ័ណ្ឌដូចខាងក្រោមនេះ៖ ១) បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខ នឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។ ២) បទល្មើស និង ការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង ៣) គ្មានវិសមមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន"។

សន្និដ្ឋានដែលខានមិនបាន គឺថា ភស្តុតាងនៅសវនាការជំនុំជម្រះសាលាដំបូងគឺពុំមានស៊ីសង្វាក់តាមផ្លូវច្បាប់ តាមអង្គហេតុ និងតាមផ្លូវចិត្តជាមួយនឹងការយល់ឃើញរបស់តុលាការដែលថា ជនជាប់ចោទបានប្រព្រឹត្តដោយធ្វេសប្រហែស មិនប្រុងប្រយ័ត្ន និងខ្ជីខ្ជានោះឡើយ។

"*ឃាតកម្ម*" ត្រូវបានផ្តល់និយមន័យនៅក្នុងមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌថា ជា "*អំពើ<u>សម្លាប់ដោយចេតនា</u> ដោយប្រើអាវុធ ឬមិនប្រើអាវុធ*"។ ការបញ្ជាក់បន្ថែមពីលក្ខខណ្ឌតម្រូវលើធាតុអត្តនោម័តិ (អត្តនោម័តិ) នៃបទមនុស្សឃាត អាចរកបាននៅក្នុងមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ដែលចែងអំពី "*អំពើហិង្សាដោយចេតនា*" នាំឲ្យមនុស្សស្លាប់។ មាត្រា ២២៤ ចែងថា៖

> "*អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ឆ្នាំ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះ បណ្តាលឲ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់*"។

ដូច្នោះហើយ ចំណុចនេះបន្តទៀតថា "*ការសម្លាប់ដោយចេតនា*" តម្រូវឲ្យមានចេតនាពិតប្រាកដពីជនជាប់ជាប់ចោទក្នុងការបង្កឲ្យស្លាប់ដល់អ្នកដទៃ។ អំពើហិង្សាដោយចេតនាដែលបង្កឲ្យមានការស្លាប់គឺ មិនមានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ សម្រាប់ធ្វើការផ្តន្ទាទោសពីបទមនុស្សឃាតនោះទេ។

ដោយពិនិត្យឃើញថា ជនរងគ្រោះ នៅរស់រានមានជីវិតពីករណីបាញ់ប្រហារ ដែលយោងតាមហេតុផលបានបង្ហាញខាងលើគឺច្បាស់ណាស់ជាការប្រព្រឹត្តអំពើហិង្សាដែលគ្រោងទុកជាមុន ករណីនេះ ចាំបាច់ក្នុងការពិចារណាថាតើភស្តុងតាងដែលបញ្ជូនទៅតុលាការ អាចនាំឲ្យមានការចោទប្រកាន់ពីបទ "*ប៉ុនប៉ងមនុស្សឃាត*" ឬយ៉ាងណា។ មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ ឲ្យនិយមន័យពាក្យ "ប៉ុនប៉ង" ហើយដែលការប៉ុនប៉ងត្រូវបានកើតឡើង នៅពេលតុលាការយល់ឃើញថាបានបំពេញតាមបទដ្ឋានចាំបាច់ កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ៖

> "*១) ចាប់បានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង*
>
> *២) ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។*"

នៅក្នុងសំណុំរឿងរបស់ជនជាប់ចោទ បទល្មើសនៃ "*ការប៉ុនប៉ងមនុស្សឃាត*" គួរតែត្រូវបានបង្កើតឡើង ប្រសិនបើទីមួយ ជនជាប់ចោទបានបង្កើតធាតុអត្តនោម័តិនៃបទល្មើសដែលច្បាប់តម្រូវ ពោលគឺ ចេតនាពិតប្រាកដក្នុងការសម្លាប់ជនដទៃ និងទីពីរត្រូវបានបំពេញតាមលក្ខខណ្ឌក្នុងមាត្រា ២៧។

ទាក់ទិនទៅនឹងផ្នែកទីមួយ ថាតើជនជាប់ចោទមានចេតនាពិតប្រាកឬយ៉ាងណាក្នុងការសម្លាប់ជនដទៃ ភស្តុតាងនៅចំពោះមុខតុលាការបានបង្ហាញថា ជនជាប់ចោទបានប្រដាប់អាវុធស្លាប់រស់ដោយគ្រោងទុកជាមុន ជនជាប់ចោទបានយកអាវុធចូលទៅក្នុងស្ថានការណ៍ដែលប្រឈមគ្នានៅរោងចក្រ នៅពេលដែលមានវត្តមាននគរបាលក្នុងការការពារសន្តិសុខផ្ទាល់ខ្លួនរបស់គាត់ និងទ្រព្យសម្បត្តិរួចទៅហើយនោះ ជនជាប់ចោទបានដើរ

ចម្ងាយពីរបីម៉ែត្រចេញពីក្រុមកម្មករ បានងាកត្រឡប់មកវិញ និងបានដកអាវុធ មុនពេលលើកវាតម្រង់ទៅកាន់ក្រុមកម្មករ ហើយបានបាញ់យ៉ាងតិចពីរគ្រាប់។ តាមគោលការណ៍ច្បាប់ និងគោលការណ៍សុភវិនិច្ឆ័យ ជនម្នាក់នេះមានបំណងបង្កជាផលវិបាកតាមរយៈសកម្មភាពរបស់ខ្លួន។ ផលវិបាកតាមរយៈសកម្មភាពរបស់ជនជាប់ចោទនោះ គឺថា មនុស្សអាចនឹងត្រូវបានសម្លាប់។

ភស្តុតាងដែលជនជាប់ចោទត្រូវបានរារាំងមិនឲ្យមានការបាញ់ប្រហារថែមទៀត ទៅកាន់ក្រុមកម្មករ ដោយសារតែកាំភ្លើងជាប់គាំងបាញ់មិនចេញ ជាភស្តុតាងដ៏សំខាន់ ដែលជាភស្តុតាងរឹតតែគួរឲ្យជឿជាក់ថែមទៀតចំពោះធាតុអត្តនោម័តិរបស់ជនជាប់ចោទនៅពេលបាញ់ប្រហារ និងពាក់ព័ន្ធទៅនឹងការបំពេញតាមលក្ខខណ្ឌនៃមាត្រា ២៧ នៃក្រមព្រហ្មទណ្ឌ។

ភស្តុតាងដែលបង្ហាញថា ជនជាប់ចោទមានបំណងបាញ់ថែមទៀត ប៉ុន្តែ មិនអាចបាញ់បានដោយសារកាំភ្លើងរបស់ខ្លួនជាប់គាំងបាញ់មិនចេញ បង្ហាញបន្ថែមថា ជនជាប់ចោទចង់ឲ្យសកម្មភាពរបស់គាត់នេះបង្កឲ្យស្លាប់ដល់ជនដទៃ។ ភស្តុតាងដែលបង្ហាញថា ជនជាប់ចោទបានឲ្យកាំភ្លើងទៅសហការីរបស់ខ្លួនដើម្បីដោះការជាប់គាំង ហើយដូច្នេះ គាត់អាចបន្តបាញ់ថែមទៀត ជាការបញ្ជាក់បន្ថែមដល់ទម្ងន់នៃភស្តុតាងដែលថាជនជាប់ចោទមានបំណងបាញ់កាំភ្លើងថែមទៀតចូលទៅកាន់ក្រុមកម្មករច្រើនជាងអ្វីដែលគាត់បានបាញ់រួចហើយ។ តាមសេចក្តីអះអាងដ៏សាមញ្ញ កាលណាកាំភ្លើងត្រូវបានបាញ់កាន់តែច្រើនគ្រាប់ ពេលនោះកាន់តែទំនង និងកាន់តែច្បាស់ដែលថាមនុស្សនឹងត្រូវស្លាប់ជាក់ជាពុំខាន។ ករណីនេះពិតមានការយល់ច្បាស់លាស់ហើយចំពោះជនជាប់ចោទ បន្ទាប់ពីការផ្ទុះអាវុធពីរបីគ្រាប់ដំបូងមុនពេលកាំភ្លើងគាត់ជាប់គាំងបាញ់មិនចេញ ដែលថា ជនជាប់ចោទបានបាញ់ចូលទៅកាន់ក្រុមកម្មករ ដែលជាការផ្ទុយទៅនឹងកំណត់ហេតុនៃចម្លើយផ្ទាល់ខ្លួនរបស់គាត់ដែលថា ខ្លួនគ្រាន់តែកាន់កាំភ្លើងភ្ជង់ទៅលើ ប៉ុន្តែពិសេសជាងនេះទៀត ជនជាប់ចោទគួរតែដឹងច្បាស់ថា ជនរងគ្រោះបានរងរបួស។ អង្គហេតុដែលថាជនជាប់ចោទមានបំណងបាញ់បន្តទៀត ប៉ុន្តែត្រូវបានអាក់ខានវិញដោយសារកាំភ្លើងរបស់គាត់ជាប់គាំងបាញ់មិនចេញ ឈានដល់ការសន្និដ្ឋានដែលមិនអាចជៀសរួចថា ជនជាប់ចោទមានបំណងសម្លាប់មនុស្ស។ សេចក្តីសន្និដ្ឋានតាមបែបសុភវិនិច្ឆ័យលើការខកខានរបស់ជនជាប់ចោទក្នុងការពន្យល់ពីមូលហេតុដែលគាត់បានរត់ និងសក្ខីកម្មរបស់សាក្សី គឺថា ជនជាប់ចោទបានបាញ់កាំភ្លើងចូលទៅក្នុងក្រុមកម្មករដោយគ្រោងទុកជាមុន ហើយបានរត់គេចខ្លួនភ្លាមខណៈដែលគាត់មិនអាចបាញ់បន្តទៀត និងកម្មករបានដេញតាមគាត់។

ភស្តុតាងបង្ហាញពីការជាប់គាំងកាំភ្លើង ក៏អាចបំពេញតាមលក្ខខណ្ឌទាំងពីរនៃបទប៉ុនប៉ងតាមមាត្រា ២៧ ផងដែរ។ លក្ខខណ្ឌទីមួយត្រូវបំពេញ ខណៈដែលជនជាប់ចោទបានចាប់ផ្តើមប្រើកម្លាំងស្លាប់រស់ និងអង្គហេតុដែលថាការបាញ់ពីរបីគ្រាប់ដំបូង មិនបានបង្កឲ្យជនរងគ្រោះ ឬជនដទៃស្លាប់ គឺជាសំណាងល្អ ហើយនេះមិនមែនដោយសារតែ កង្វះចេតនារបស់ជនជាប់ចោទនោះទេ។ តាមរយៈការបែរមុខទៅរកកម្មករ ការដក និងលើកកាំភ្លើង ព្រមទាំងការបាញ់ម្តងហើយម្តងទៀត ជនជាប់ចោទបានប្រព្រឹត្តហួសដំណាក់កាលត្រៀមបម្រុង

និងបានចាប់ផ្តើមប្រព្រឹត្តបទល្មើសនោះតែម្តង។ ភស្តុតាងបញ្ជាក់ពីចេតនារបស់ជនជាប់ចោទក្នុងការបន្តប្រើកម្លាំងស្លាប់រស់ តែត្រូវបានអាក់ខានទៅវិញដោយសារតែកាំភ្លើងជាប់គាំង បំពេញលក្ខខណ្ឌទីពីរនៃមាត្រា ២៧។ ជនជាប់ចោទមិនបានបញ្ឈប់ការបាញ់តាមឆន្ទៈរបស់ខ្លួននោះទេ ប៉ុន្តែ "*តាមរយៈកាលៈទេសៈហួសពីការគ្រប់គ្រងរបស់ខ្លួន*"។

ហេតុដូច្នោះហើយ ការវិភាគផ្លូវច្បាប់នេះ ធ្វើសេចក្តីសន្និដ្ឋានលើការពិនិត្យពិចារណា ១) ភាពរឹងមាំនៃភស្តុតាងដែលបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តដោយចេតនា មិនមែនជាការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជានោះទេ ២) ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដែលបង្កឡើងតាមរយៈសកម្មភាពរបស់ជនជាប់ចោទ និងផលវិបាកសំខាន់ដែលមិនអាចប្រកែកបាន ដែលថាអាវុធរបស់ជនជាប់ចោទមិនអាចដោះការជាប់គាំងបាន និង ៣) ភស្តុតាងដែលគាំទ្រពីចេតនារបស់ជនជាប់ចោទក្នុងការសម្លាប់ ជាជាង គ្រាន់តែបង្កឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជនរងគ្រោះ និងអ្នកដទៃនៅក្នុងក្រុមកម្មកររោងចក្រកៅស៊ូ ការចោទប្រកាន់ដ៏ត្រឹមត្រូវប្រឆាំងនឹងជនជាប់ចោទគួរតែពីបទ "*ប៉ុនប៉ងមនុស្សឃាត*"។ សូម្បីតែមានទឡ្ហីករណ៍លើកឡើងថា ភស្តុតាងបានបង្ហាញពីចេតនាយ៉ាងច្បាស់របស់ជនជាប់ចោទក្នុងការសម្លាប់ ដូច្នេះយ៉ាងហោចណាស់តុលាការគួរតែពិចារណាលើការចោទប្រកាន់ពីបទ "*ហិង្សាដោយចេតនា*" ដែលមានស្ថានទម្ងន់ទោសដោយការប្រើប្រាស់អាវុធ។

**នីតិវិធីបណ្តឹងឧទ្ធរណ៍**

បើទោះជាជនជាប់ចោទ មិនទាន់ត្រូវបានចាប់ខ្លួនតាមផ្លូវច្បាប់ បន្ទាប់ពីការចោទប្រកាន់ និងផ្តន្ទាទោសដោយ*កំបាំងមុខ*ក្តី ជនជាប់ចោទអាចប្តឹងឧទ្ធរណ៍បាន ហើយប្រាកដណាស់ថាមានទំនាក់ទំនងគ្នាជាមួយនឹងក្រុមគ្រួសារ និងក្រុមមេធាវីការពារក្តីរបស់ខ្លួន ដែលចោទជាចម្ងល់ថាតើអាជ្ញាធរពិតជាកំពុងតែធ្វើអ្វីគ្រប់យ៉ាងតាមអំណាចរបស់ខ្លួនដើម្បីជានាដល់ការចាប់ខ្លួនជនជាប់ចោទឬយ៉ាងណា។[28]

សាលាឧទ្ធរណ៍បានបើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ សហជនជាប់ចោទ និងភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៣។ ចៅក្រមសាលាឧទ្ធរណ៍ (ចៅក្រម តាំង ស៊ុនឡាយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ចៅក្រម ប្លង់ សំណាង និងចៅក្រម អ៊ុំ សារិទ្ធ) ដូច សមភាគី នៅសាលាដំបូងខេត្តស្វាយរៀង បានសម្រេចធ្វើការពិនិត្យស្វែងរកជនដែលទទួលខុសត្រូវបាញ់ជនរងគ្រោះឲ្យរបួសជាជាងការទទួលយកទម្ងន់នៃភស្តុតាងដែលបង្ហាញពីអំពើដោយចេតនារបស់ជនជាប់ចោទ។ ដូច្នេះ សាលាឧទ្ធរណ៍ខកខានពុំបានផ្តល់ឱកាសរកយុត្តិធម៌ពិតប្រាកដជូនជនរងគ្រោះ និងពុំបានបង្ហាញឲ្យបានត្រឹមត្រូវនូវឥរិយាបថនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដោយការជំនួសបទចោទប្រកាន់ឲ្យបានធ្ងន់ធ្ងរជាងនេះ។

[28] ម៉ៃ ទិត្យធារ៉ា "បណ្ឌិត ប្តឹងឧទ្ធរណ៍ខណៈដែលកំពុងគេចខ្លួន" កាសែត *ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣)។

លោក កែ វិសាល មេធាវីការពារជនជាប់ចោទ បានថ្លែងប្រាប់សាលាឧទ្ធរណ៍ថា កូនក្តីរបស់ខ្លួនបាន ដឹងពីសវនាការឧទ្ធរណ៍ ប៉ុន្តែមិនបានផ្តល់ព័ត៌មានលម្អិតពីកន្លែងដែលជនជាប់ចោទស្ថិតនៅនោះទេ។ មេធាវីរបស់ជនជាប់ចោទបានថ្លែងនៅក្នុងសវនាការនោះថា អតីតអភិបាលក្រុងបាវិតមិនមានការទទួលខុសត្រូវណាមួយចំពោះករណីបាញ់ប្រហារនោះទេ ដោយពុំមានជនណាម្នាក់បានឃើញជនជាប់ចោទបាញ់កាំភ្លើង ហើយបានព្យាយាមដាក់ការទទួលខុសត្រូវក្នុងការធ្វើឲ្យរបួសដល់ជនរងគ្រោះលើនគរបាល និងកងសន្តិសុខនៅទីនោះ។ ជួសមុខឲ្យកូនក្តីរបស់ខ្លួន ស្របជាមួយនឹងអ្វីដែលគាត់មាននៅសវនាការសាលាដំបូង មេធាវី កែ វិសាល បានព្យាយាមសំដៅលើកំណត់ហេតុនៃចម្លើយ ដែលកូនក្តីរបស់ខ្លួនបានផ្តល់ទៅចៅក្រមស៊ើបសួរនៅខេត្តស្វាយរៀង ដែលបានលើកឡើងថា ជនជាប់ចោទមិនបានបាញ់កាំភ្លើងណាមួយ ហើយគាត់គ្រាន់តែបានលើកកាំភ្លើងទាំងគាត់បានដឹងថាកាំភ្លើងនោះគាំងបាញ់មិនកើត ក្នុងគោលបំណងដើម្បីទប់ស្កាត់កុំឲ្យក្រុមកម្មករចោលដុំថ្មដាក់គាត់។

សាក្សីចំនួនជាង ៥០ នាក់ ត្រូវបានសាលាឧទ្ធរណ៍កោះហៅដើម្បីផ្តល់ភស្តុតាងនៅសវនាការ។ ខណៈដែលអ្នកខ្លះមិនបានជូនដីកាត្រឡប់មកវិញថាបានទទួលដីកាកោះរបស់តុលាការ សាក្សីជាច្រើនផ្សេងទៀតមិនបានមកចូលរួមសវនាការដើម្បីផ្តល់សក្ខីកម្មដល់សាលាឧទ្ធរណ៍នោះទេ។សាក្សីដែលបានបង្ហាញខ្លួនដើម្បីផ្តល់ភស្តុតាងផ្ទាល់ មានជនរងគ្រោះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងមន្ត្រីកងរាជអាវុធហត្ថម្នាក់ ព្រមទាំងមន្ត្រីនគរបាលមូលដ្ឋានពីរនាក់ ដែលបានយាមនៅរោងចក្រកៅវ៉េ នៅព្រឹកថ្ងៃបាញ់ប្រហារនោះ។

សក្ខីកម្មដែលបានផ្តល់ដោយ នុត សាខន គឺជាប្រភេទនៃភស្តុតាង ដែលជនរងគ្រោះខ្លួនឯងអាចផ្តល់ឲ្យបាន។ នាងបានផ្តល់ភស្តុតាងបញ្ជាក់ថា នាងបានត្រូវគេបាញ់ចំពីក្រោយខ្នង ខណៈដែលនាងឈរនៅជិតបន្ទប់ទឹកខាងក្នុងបរិវេណរោងចក្រកៅវ៉េ ហើយមិនបានឃើញជនដែលបានបាញ់នាង និងកម្មករដទៃទៀតនោះទេ។ នុត សាខន ដំបូងឡើយបានគិតថា នាងត្រូវដុំថ្មដែលចោលដោយកម្មករដទៃទៀត ប៉ុន្តែក្រោយមកត្រូវបានគេប្រាប់ថា ជនជាប់ចោទបានបាញ់ប្រហារមកលើនាង និង និងកម្មករដទៃទៀត។ សំណួរដែលបានចោទសួរដោយចៅក្រមសាលាឧទ្ធរណ៍បានបង្ហាញថា តុលាការមានការព្រួយបារម្ភអំពីសកម្មភាពនៃការតវ៉ារបស់កម្មកររោងចក្រ ច្រើនជាងសកម្មភាពរបស់ជនជាប់ចោទ។

វរសេនីត្រីយ៍ កែវ សុខន បានប្រាប់ចៅក្រមសាលាឧទ្ធរណ៍ថា គាត់បានឃើញជនជាប់ចោទកាន់កាំភ្លើងបន្ទាប់ពីការបាញ់ប្រហារនោះ ហើយគាត់បានជួយជនជាប់ចោទឲ្យគេចខ្លួនខណៈដែលកម្មករចាប់ផ្តើមដេញតាមអតីតអភិបាលក្រុង។ គាត់បានផ្តល់សក្ខីកម្មថា នគរបាលមិនបានបាញ់ទេ ប៉ុន្តែថា គាត់ក៏មិនបានឃើញជនជាប់ចោទបាញ់ដែរ។ តែយ៉ាងណាក្តី គាត់បានបញ្ជាក់ពីព្រឹត្តិការណ៍នោះតាមលំដាប់លំដោយថា គាត់បានឮស្នូរផ្ទុះអាវុធ បន្ទាប់មកជនជាប់ចោទបានរត់ ហើយក្រោយមកទៀត ពុំមានឮសំឡេងផ្ទុះអាវុធទៀតនោះទេ។ ភស្តុងតាងរបស់លោកវរសេនីត្រីយ៍ រាជ ជំនិត គឺថា គាត់បានឃើញជនជាប់ចោទដើរចូលទៅកាន់អ្វីដែលគាត់បានរៀបរាប់ថា ជា "ក្រុមមនុស្សកុះករ" ហើយភ្ជង់កាំភ្លើងគាត់តម្រង់ទៅរកកម្មករ ប៉ុន្តែ គាត់បានអះអាង

ផងដែរថា មិនបានឃើញមានការផ្ទុះអាវុធនៅពេលនោះទេ ប៉ុន្តែបានបញ្ជាក់ជាថ្មីថា គ្មាននរណាផ្សេងទៀតបានបាញ់កាំភ្លើងទេ។ សាក្សីនេះក៏បានបញ្ជាក់ផងដែរថា បន្ទាប់ពីជនជាប់ចោទបានគៀសខ្លួនចេញទៅ គាត់បានឃើញកាំភ្លើងដែលជនជាប់ចោទបានក្តង់ដាក់ក្រុមកម្មករ ហើយបានបញ្ជាក់ថាកាំភ្លើងនោះជាប់គាំងបាញ់មិនចេញទេ។[29]

នៅសវនាការជំនុំជម្រះចំពោះសាលាដំបូងខេត្តស្វាយរៀង តុលាការបានស្តាប់សក្ខីកម្មរបស់អធិការរងនគរបាលឃុំ ប្រាសាទ គឺលោក ឡុង ធន។ លោក ឡុង ធន គឺជាសាក្សីម្នាក់ដែលរំពឹងថានឹងចូលរួមសវនាការ ប៉ុន្តែបានខកខានពុំបានចូលខ្លួនឆ្លើយបំភ្លឺ។ យ៉ាងណាក៏ដោយ ភស្តុតាងរបស់គាត់ត្រូវបានអាននៅក្នុងសាលាឧទ្ធរណ៍ ដែលបានបញ្ជាក់ថា គាត់បានឃើញជនជាប់ចោទក្តង់កាំភ្លើងតម្រង់ដាក់កម្មករ និងកេះកៃកាំភ្លើង ហើយបានឃើញជនរងគ្រោះដួលទៅលើដី។[30]

ទោះបីជា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ បានស្នើឲ្យសាលាឧទ្ធរណ៍ពិចារណាលើការប្តូរបទចោទប្រកាន់លើជនជាប់ចោទមកជា *"បទប៉ុនប៉ងមនុស្សឃាត"* វិញនៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ក៏ដោយ ចៅក្រមបានចំណាយពេលវេលាតិចតួចណាស់ក្នុងការពិនិត្យពីចរិតលក្ខណៈនៃសកម្មភាពដោយចេតនារបស់ជនជាប់ចោទ។ បរិយាកាសនៃសវនាការឧទ្ធរណ៍គឺត្រូវបានបង្ហាញយ៉ាងច្បាស់ពីការពុំសូវចាប់អារម្មណ៍របស់តំណាងមហាអយ្យការ លោក អ៊ឹម សុផាន ដែលការចូលរួមចំណែករបស់លោកយ៉ាងច្រើនក្នុងដំណើរការនីតិវិធី គឺដើម្បីជំទាស់ទៅនឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានពិពណ៌នាដឹកមុខថាជនជាប់ចោទគឺជាអ្នកទទួលខុសត្រូវ នៅពេលដែលជនរងគ្រោះពិតជាមិនបានឃើញជនដែលបានបាញ់កាំភ្លើងធ្វើឲ្យរងរបួសដល់ពួកគេនោះ។ ព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ដោយខ្លីថា សវនាការឧទ្ធរណ៍ធ្វើឡើងដោយសារមានបណ្តឹងឧទ្ធរណ៍ពីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ហើយមិនបានបញ្ជាក់ថាសកម្មភាពរបស់ជនជាប់ចោទមានលក្ខណៈធ្ងន់ធ្ងរជាងការ *"បង្ករបួសស្នាមដោយអចេតនា"* បើទោះជាមានភស្តុតាងជាច្រើននៅចំពោះមុខសាលាដំបូងខេត្តស្វាយរៀង និងសាលាឧទ្ធរណ៍យ៉ាងណាក្តី។

នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ សាលាឧទ្ធរណ៍បានសាលដីការបស់ខ្លួនពាក់ព័ន្ធនឹងសវនាការកាលពីសប្តាហ៍មុន ហើយបានបញ្ជាក់ពីការផ្តន្ទាទោសលើជនជាប់ចោទពីបទ *"បង្ករបួសស្នាមដោយអចេតនា"* និងការផ្តន្ទាទោសលើសហជនជាប់ចោទពីបទ *"ប្រើប្រាស់អាវុធខុសច្បាប់"*។ ទណ្ឌកម្មកំណត់ដោយសាលាឧទ្ធរណ៍នៅតែមិនមានការផ្លាស់ប្តូរពីទោសពន្ធនាគារ ប្រាក់ពិន័យ និងសំណងដែលបានសម្រេចដោយសាលាដំបូងខេត្តស្វាយរៀងឡើយ។

---

29 ខៃ សុវុទ្ធី 'ឈូក បណ្ឌិត នៅតែមិនបង្ហាញខ្លួនរយៈពេល២០ខែហើយ បន្ទាប់ពីបាញ់កម្មកររោងចក្រ' *ដឹ ខេមបូឌា ដេលី* (ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣)។

30 មានប្រភពដូចខាងលើ

**ការវិភាគលើនីតិវិធីតុលាការ**

សេចក្តីសន្និដ្ឋាននៃអត្ថបទវិភាគផ្លូវច្បាប់នេះ គឺថាអាជ្ញាធរខេត្តស្វាយរៀង និងសាលាឧទ្ធរណ៍មិនបាន អើពើអំពីភស្តុងតាងនៅចំពោះមុខខ្លួនដែលភស្តុតាងនោះបង្ហាញថា ជនជាប់ចោទបានប្រឈមនឹងកម្មកររោង ចក្រកៅវ៉េជាមួយនឹងអាវុធខ្លីដោយគ្រោងទុកជាមុន និងមានគោលបំណងបាញ់ម្តងហើយម្តងទៀតចូលទៅក្នុង ក្រុមកម្មករ ដែលធ្វើឲ្យរបួសធ្ងន់ដល់ជនរងគ្រោះដែលពុំមានអ្វីត្រូវបង្កការគំរាមកំហែងចំពោះគាត់ ឬពាក់ព័ន្ធ ដោយផ្ទាល់នៅក្នុងបែបផែននៃតវ៉ាទាមទារណាមួយនោះទេ។

ការចោទប្រកាន់ពីបទ *"បង្ករបួសស្នាមដោយអចេតនា"* និងការផ្តន្ទាទោសជាបន្តបន្ទាប់លើជនជាប់ ចោទនោះ គឺដោយសារតែមានសម្ពាធពីសង្គមស៊ីវិល។ ប្រការនេះ ពិបាកនឹងគេចចេញពីសេចក្តីសន្និដ្ឋានដែល ថា ការផ្តន្ទាទោសនេះជាកម្រិតអប្បបរមាដែលស្ថាប័នអយ្យការ និងតុលាការ អាចធ្វើទៅបាន នៅពេលបានជួប នូវស្ថានការណ៍មួយដែលជនជាប់ចោទជាបុគ្គលស្និទ្ធនឹងរដ្ឋាភិបាល ប៉ុន្តែពួកគេមានការប្រឈមនឹងការខឹង សម្បារបស់សាធារណជន ដែលការចោទប្រកាន់លើជនជាប់ចោទទាំងអស់ត្រូវបានទម្លាក់ចោលពីលើកដំបូង។

ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង ពិតជាមានការស្ទាក់ស្ទើរក្នុងការស៊ើបអង្កេតនូវសកម្មភាព នានារបស់អ្នកនយោបាយថ្នាក់មូលដ្ឋានដែលស្និទ្ធជាមួយនឹងរដ្ឋាភិបាល ដោយធ្វើមិន អើពើនឹងកំណត់ហេតុនៃ ព្រឹត្តិការណ៍របស់នគរបាល និងសូម្បីតែមានការសារភាពរបស់ជនជាប់ចោទផ្ទាល់នោះក្តី។ តំណាងអយ្យការ និងសាលាខេត្ត បានពាក់ព័ន្ធក្នុងនីតិវិធីបង្វិលទៅបង្វិលមក ខណៈធ្វើការព្យាយាម "បញ្ជាក់" ភស្តុតាងរបស់ ជនរងគ្រោះ និងផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ជនជាប់ចោទដើម្បីផ្លាស់ប្តូរកំណត់ហេតុនៃចម្លើយរបស់ខ្លួន។ ជាក់ស្តែង ទាំងព្រះរាជអាជ្ញា និងតុលាការមិនចង់ឲ្យរឿងនោះដំណើរការទៅមុខទេ ហើយបានធ្វើដោយស្ទាក់ ស្ទើរ ព្រមទាំងធ្វើដោយស្ថិតនៅក្រោម សម្ពាធពីប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន និងសង្គមស៊ីវិលតែប៉ុណ្ណោះ។

សូម្បីតែនៅពេលសំណុំរឿងនេះបានដំណើរការ ព្រះរាជអាជ្ញាខេត្ត និងចៅក្រមស៊ើបសួរបានព្យាយាម ការពារមិនឲ្យជនជាប់ចោទប្រឈមនឹងយុត្តិធម៌។ សេចក្តីសម្រេចមិនធ្វើការឃុំខ្លួនបណ្តោះអាសន្ន សេចក្តី សម្រេចក្នុងការចោទប្រកាន់ជនជាប់ចោទត្រឹមតែពីបទ *"បង្ករបួសស្នាមដោយអចេតនា"* បើទោះជាភស្តុតាង ជាក់បន្ទុកបានបង្ហាញពីសកម្មភាពគ្រោងទុកជាមុនរបស់ជនជាប់ចោទនោះក្តី និងសេចក្តីសម្រេចដែលមិនអាច អត់ឱនឲ្យបានចំពោះការព្យាយាមទម្លាក់ការទទួលខុសត្រូវលើសហជនជាប់ចោទពីករណីបាញ់ប្រហារ និង ទម្លាក់បទចោទលើជនជាប់ចោទចំពោះមុខភស្តុតាងដែលបង្ហាញពីការទទួលខុសត្រូវរបស់ជនជាប់ចោទតែម្នាក់ ហើយព្រមទាំងការបដិសេធមិនទទួលខុសត្រូវរបស់សហជនជាប់ចោទ បញ្ហាទាំងអស់នេះចង្អុលទៅស្ថាប័ន តុលាការថាពុំមានសមត្ថភាព និងលម្អៀង។

សាលាឧទ្ធរណ៍បានបង្ហាញនូវភាពលម្អៀងដូចគ្នា។ បើទោះជាមានការបង្គាប់កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ឲ្យសាលាដំបូងខេត្តស្វាយរៀងជំនុំជម្រះលើជនជាប់ចោទក្តី នៅដំណាក់កាលនេះសាលាឧទ្ធរណ៍ បានខកខានក្នុងការជំនួសបទចោទប្រកាន់ដែលបង្ហាញឲ្យបានត្រឹមត្រូវពីឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ ពោលគឺ

"*ការប៉ុនប៉ងមនុស្សឃាត*" ឬ "*អំពើហិង្សាដោយចេតនា*" ដែលត្រូវកំណត់នូវកម្រិតមួយសម្រាប់សវនាការជំនុំជម្រះសាលាដំបូងនៅខែមិថុនា និងសវនាការឧទ្ធរណ៍នៅខែវិច្ឆិកា ឆ្នាំ២០១៣។ ការចោទប្រកាន់ពីបទ "*បង្ករបួសស្នាមដោយអចេតនា*" ជាកម្រិតអប្បបរមាដែលសាលាឧទ្ធរណ៍អាចសម្រេចទៅកើត នៅចំពោះមុខភស្តុតាងដែលមាន និងការទាមទារពីសាធារណជនចំពោះការទម្លាក់ចោលបទចោទប្រកាន់លើជនជាប់ចោទនៅក្នុងខែធ្នូ ឆ្នាំ២០១២។ សាលាដំបូងខេត្តស្វាយរៀង និងក្រោយមក សាលាឧទ្ធរណ៍ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ គ្មានបំណងក្នុងការពិចារណាលើបទចោទឲ្យបានត្រឹមត្រូវចំពោះសកម្មភាពរបស់ជនជាប់ចោទនោះទេ។

ទោះបីជាមានការផ្តល់សំណងទៅជនរងគ្រោះ ដែលអាចជាផ្នែកនៃការសងជំងឺចិត្ត និងការខូចខាតព្រមទាំងការបាត់បង់ឱកាសរកប្រាក់ចំណូលយ៉ាងណាក្តី ជនរងគ្រោះនៅតែមិនទទួលបានអ្វីនោះទេ ល្អិតណាអាជ្ញាធរចាត់វិធានការឲ្យបានត្រឹមត្រូវក្នុងការចាប់ខ្លួនជនជាប់ចោទ។ ម្យ៉ាងវិញទៀត ការសងជំងឺចិត្តតែម្យ៉ាងមិនទាន់គ្រប់គ្រាន់ក្នុងការឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវពីទំហំនៃភាពធ្ងន់ធ្ងររបស់ជនរងគ្រោះដែលរងរបួស ឬក៏សកម្មភាពនៃបទឧក្រិដ្ឋដែលគ្រោងបានទុករបស់ជនជាប់ចោទនោះទេ។ ថ្លៃព្យាបាលរបួសរបស់ជនរងគ្រោះត្រូវបានចេញដោយក្រុមហ៊ុនផលិតស្បែកជើងកីឡាអន្តរជាតិម៉ាក ពូម៉ា ដែលផលិតផលស្បែកជើងកីឡារបស់ក្រុមហ៊ុននេះ បានផលិតនៅរោងចក្រកៅវ៉េ បន្ទាប់ពីមានការតវ៉ាយ៉ាងខ្លាំងជាអន្តរជាតិចំពោះឧបទ្ទវហេតុនោះ។[31] រហូតមកដល់ពេលនេះ ជនជាប់ចោទបានរួចផុតពីទណ្ឌកម្មចំពោះសកម្មភាពរបស់ខ្លួនកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ទោះបីជាត្រូវបានផ្តល់សិទ្ធិយ៉ាងពេញលេញនៅពេលជំនុំជម្រះនៅចំពោះមុខសាលាដំបូងខេត្តស្វាយរៀង និងសាលាឧទ្ធរណ៍ និងថ្វីបើមេធាវីការពាររបស់ជនជាប់ចោទនៅតុលាការលើកឡើងខុសគ្នាជាច្រើនពីចម្លើយដែលជនជាប់ចោទបានផ្តល់ពីដំបូងដែលជាផ្នែកនៃការស៊ើបអង្កេត។

## ៥. នីតិវិធីជំនុំជម្រះ និងការរំលោភបំពានច្បាប់អន្តរជាតិ

មាត្រា ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ដាក់កាតព្វកិច្ចមួយលើរដ្ឋាភិបាល ដែលជារដ្ឋភាគីក្នុងការការពារសេចក្តីថ្លៃថ្នូរ និងបូរណភាពផ្លូវកាយ និងផ្លូវចិត្តរបស់បុគ្គលគ្រប់រូប។ កាតព្វកិច្ចពង្រីកដល់ការការពារចំពោះបុគ្គលគ្រប់រូបពីអំពើរំលោភបំពានរបស់ជនដែលបំពេញមុខនាទីជារាជការ មិនមាននាទីជារាជការ ឬរូបវន្តបុគ្គលណាក៏ដោយ។

ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនតាមមាត្រា ៧ នៃ "ក.អ.ស.ព.ន" នេះមិនទាន់គ្រប់គ្រាន់សម្រាប់រដ្ឋាភិបាលដើម្បីបង្ហាញថា អំពើហិង្សាលើបុគ្គលបានត្រូវផ្តន្ទាទោសព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ប៉ុន្តែ ថា រដ្ឋាភិបាល ត្រូវផ្តល់នូវសំណងជំងឺចិត្តសមរម្យ និងធានាថា "*គ្រប់ពាក្យបណ្តឹងត្រូវតែស៊ើបអង្កេតជា*

[31] សេចក្តីថ្លែងការណ៍របស់ក្រុមហ៊ុន ពូម៉ា (ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២) អាចរកបានតាម៖ <http://about.puma.com/puma-covers-medical-treatment-costs-for-injured-employee-of-its-footwear-supplier-kaoway-sports-ltd/>។

*បន្ទាន់ និងដោយឥតលម្អៀង ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីបង្កើតនូវដំណោះស្រាយដោយប្រសិទ្ធភាព"*។[32]

មាត្រា ១៤ (១) នៃ ក.អ.ស.ព.ន ចែងថា៖

*"ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តី មានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យរដ្ឋប្បវេណី"*។

យ៉ាងណាក្តី ការអនុគ្រោះ និងការអត់ឱនដល់ជនជាប់ចោទ ដែលជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ត្រូវបានធ្វើឡើងដោយសាលាដំបូងខេត្តស្វាយរៀង និងសាលាឧទ្ធរណ៍នាំឲ្យមានការសង្ស័យពីគោលបំណងរបស់តុលាការកម្ពុជាក្នុងការបំពេញតួនាទីស្របតាមបទប្បញ្ញត្តិច្បាប់អន្តរជាតិទាំងនេះ។

បញ្ហាមកពី ១) កង្វះវិធានការឃុំខ្លួនជាបណ្តោះអាសន្នលើជនជាប់ចោទ ២) ការទម្លាក់បទចោទប្រកាន់លើជនជាប់ចោទកាលពីដំបូង ដែលត្រូវបានអនុវត្តឡើងវិញដោយសារមានសម្ពាធពីអង្គការមិនមែនរដ្ឋាភិបាល និងតំណាងសង្គមស៊ីវិល ៣) ការបន្ធូរបន្ថយបទចោទប្រកាន់ បើទោះជាមានការចោទប្រកាន់ធ្ងន់ធ្ងរលើជនជាប់ចោទ និងចុងក្រោយ ៤) ការខកខានរបស់អាជ្ញាធរកម្ពុជាក្នុងការស្វែងរកឲ្យសកម្មក្នុងការចាប់ខ្លួនជនជាប់ចោទ ចង្អុលបង្ហាញពីប្រព័ន្ធតុលាការ និងប្រព័ន្ធនីតិប្រតិបត្តិដែលមិនបានផ្តល់ដំណោះស្រាយប្រកដោយប្រសិទ្ធភាពដល់ជនរងគ្រោះចំពោះការខូចខាតផ្នែករាងកាយដ៏ធ្ងន់ធ្ងរដែលពួកគេបានទទួលរង និងបានខកខានក្នុងការស៊ើបអង្កេតភ្លាមៗ និង ដោយមិនលម្អៀងចំពោះហេតុការណ៍នៃការបាញ់ប្រហារ។ បន្ថែមពីលើនេះទៀត តុលាការបានខកខានក្នុងការគោរពតាមគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់។

អវត្តមានសាលាជម្រះក្តីមួយប្រកបដោយសមត្ថភាព ឯករាជ្យ និងឥតលម្អៀង គឺកាន់តែបង្ហាញច្បាស់នៅពេលយើងធ្វើការប្រៀបធៀបរវាងការប្រព្រឹត្តរបស់តុលាការលើជនជាប់ចោទ និងការប្រព្រឹត្តរបស់តុលាការលើបុគ្គលនានាដែលមិនមែនជាមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល ដូចជាសហជនជាប់ចោទជាដើម។ ការចោទប្រកាន់លើសហជនជាប់ចោទ និងភាពរឹងរូសជាបន្តបន្ទាប់របស់ព្រះរាជអាជ្ញាខេត្តដែលថា សហជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះការបង្ករបួសស្នាម យ៉ាងហោចណាស់លើរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះទាំងអស់ ថ្វីបើខ្វះខាតភស្តុតាងស៊ីសង្វាក់ជាក់លាក់ និងគួរឲ្យជឿជាក់ ហើយនិងនៅចំពោះមុខទម្ងន់នៃភស្តុតាងជាក់បន្ទុកដែលបានមកពីសាក្សីដទៃទៀតចង្អុលបង្ហាញទៅតុលាការដែលមានភាពលម្អៀង។

សរុបមក នីតិវិធីស៊ើបសួរ នីតិវិធីជំនុំជម្រះនៅសាលាដំបូង និងនីតិវិធីនៅសាលាឧទ្ធរណ៍បានរំលោភបំពានលើសិទ្ធិមួយចំនួនរបស់ជនរងគ្រោះតាមមាត្រា ៧ នៃ ក.អ.ស.ព.ន ដែលជនរងគ្រោះមានសិទ្ធិទទួលបានការស៊ើបអង្កេតជាបន្ទាន់ និងដោយឥតលម្អៀងចំពោះអំពើហិង្សាដែលបង្កលើខ្លួន ព្រមទាំងត្រូវទទួលបាន

[32] គណៈកម្មការសិទ្ធិមនុស្សរបស់ អ.ស.ប សេចក្តីអត្ថាធិប្បាយលេខ.២០

នូវសំណងដ៏ត្រឹមត្រូវ។ ការប្រព្រឹត្តដោយមានការអត់ឱនលើជនជាប់ចោទ និងការព្យាយាមប្រើប្រាស់សហជនជាប់ចោទជាអ្នកទទួលកំហុសជំនួសបង្ហាញនូវការរំលោភបំពានយ៉ាងច្បាស់លើមាត្រា ១៤ (១)។

## ៦. សេរីភាពជាមូលដ្ឋាន

នៅក្នុងការទាមទារតំឡើងប្រាក់ឈ្នួលក្នុងអំឡុងការតវ៉ានៅខែកុម្ភៈ ឆ្នាំ២០១២ ជនរងគ្រោះបានអនុវត្តសិទ្ធិ សេរីភាពនៃការបញ្ចេញមតិ និង សេរីភាពនៃការប្រមូលផ្តុំ ដែលជាសិទ្ធិមូលដ្ឋានត្រូវបានធានាដល់ប្រជាពលរដ្ឋគ្រប់រូប ហើយក៏មានសិទ្ធិផងដែរក្នុងការរិះគន់សកម្មភាពផ្នែកពាណិជ្ជកម្ម និងសកម្មភាពរបស់រដ្ឋាភិបាល ព្រមទាំងអាចបញ្ចេញនូវការមិនពេញចិត្តជាសមូហភាពតាមរយៈការតវ៉ាដោយសន្តិវិធី។ សិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពខាងការប្រមូលផ្តុំត្រូវបានការពារក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ។

តាមច្បាប់កម្ពុជា មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ("រដ្ឋធម្មនុញ្ញ" ) ធានាថា " *ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន....សេរីភាពខាងការប្រជុំ*" ខណៈដែល មាត្រា ២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩ (ដែលដឹងថាជា "ច្បាប់បាតុកម្ម") ចែងអំពីការ *"ធានាសេរីភាពបញ្ចេញ [ដល់] ប្រជាពលរដ្ឋខ្មែរគ្រប់រូប"*។

បន្ថែមលើនេះ មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញតម្រូវឲ្យរដ្ឋាភិបាលគោរពនូវសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម" ) របស់អង្គការសហប្រជាជាតិ និងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សនានារបស់អង្គការសហប្រជាជាតិដែលបានផ្តល់សច្ចាប័នដោយរដ្ឋាភិបាលបញ្ចូលទៅក្នុងច្បាប់ជាតិរួមទាំង ក.អ.ស.ព.នផងដែរ។ ករណីនេះត្រូវបានពង្រឹងបន្ថែមតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ដែលបានប្រកាសថាសន្ធិសញ្ញាពាក់ព័ន្ធនឹងសិទ្ធិមនុស្សទាំងអស់ដែលកម្ពុជាទទួលយក បង្កើតបានជាផ្នែកមួយនៃច្បាប់ជាតិ។ [33] ហេតុដូច្នេះ ប្រជាពលរដ្ឋ គួរអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតាម មាត្រា ១៩ និង មាត្រា ២០ នៃ ស.ស.ស.ម. ព្រមទាំងមាត្រា ១៩ និងមាត្រា ២១ នៃ ក.អ.ស.ព.ន ដែលលើកកម្ពស់សិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ ។

សិទ្ធិសេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិសេរីភាពខាងការជួបប្រជុំ មិនមែនជាសិទ្ធិដាច់ខាតទេ ហើយអាចត្រូវបានរឹតត្បិតតាមកាលៈទេសៈពិសេសជាក់លាក់ ដរាបណា ការរឹតត្បិតនេះមានសមាមាត្រ ដែលអនុញ្ញាតដោយច្បាប់ និងជាករណីចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ។ [34] ដូច្នោះ ការតបតរបស់អាជ្ញាធរចំពោះបាតុកម្មនៅរោងចក្រកៅរ៉េ ដែលបង្ហាញពីការប្រែក្លាយជាហិង្សានៅពេលនោះ និងដែលសកម្មភាពរបស់កម្មករអាចបង្កើតឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ (នេះជាទិដ្ឋភាពមួយនៃករណីដែលស្ថិតនៅក្រៅវិសាលភាពនៃការវិភាគផ្លូវច្បាប់នេះ ប៉ុន្តែគួរតែត្រូវបានស៊ើបអង្កេតដោយឯករាជ្យ) ចាំបាច់ត្រូវតែមានសមា

---

[33] ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា នៅក្នុងឆ្នាំ២០០៧ (០៩២ /០០៣/២០០៧)។

[34] មាត្រា ១៩ កថាខ័ណ្ឌទី៣ និងមាត្រា ២១ នៃ ក.អ.ស.ព.ន។

មាត្រ និងជាករណីចាំបាច់ ដើម្បីប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដរាបណា ជនជាប់ចោទបំពេញតួនាទីជួសមុខឲ្យរដ្ឋក្នុងឋានៈខ្លួនជាអភិបាលក្រុងបាវិត ដែលបានបាញ់ប្រហារដោយមិនញញើតចូលទៅក្នុងក្រុមកូដករដោយសន្តិវិធី បើទោះជាមានអំពើហិង្សាកំពុងតែកើតឡើងនៅកន្លែងខ្លះក្នុងបរិវេណក្បែររោងចក្រក្តី មិនអាចជាករណីចាំបាច់ ឬជាមធ្យោបាយការពារសមាមាត្រក្នុងការរក្សាសណ្តាប់ធ្នាប់នៅក្នុងអំឡុងពេលបាតុកម្មជាសាធារណៈនោះទេ។ ជាងនេះទៅទៀត បើទោះជាជនជាប់ចោទមានតួនាទីជាអភិបាលក្រុងក្តី នេះមិនមែនជាភារកិច្ចរបស់ជនជាប់ចោទក្នុងការបញ្ឈប់ការតវ៉ានោះទេ (តែនេះជាតួនាទីរបស់កងកម្លាំងសន្តិសុខជាតិ)។

## ៧. សេចក្តីសន្និដ្ឋាន

ស្ថាប័នអយ្យការមានភាពទន់ខ្សោយ និងបានបរាជ័យក្នុងការកសាងសំណុំរឿងដ៏មាំទាំប្រឆាំងនឹងជនជាប់ចោទ បើទោះជា មានភស្តុតាងជាច្រើនយ៉ាងណាក្តី។ ការផ្តន្ទាទោស និងការតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងដោយសាលាឧទ្ធរណ៍គឺធ្វើទៅដោយសារតែមានសម្ពាធពីសាធារណៈជន ជាជាងការបំពេញមុខងារជាតុលាការប្រកបដោយភាពរឹងមាំ ឯករាជ្យ និងមិនលម្អៀង។ ការពុំមានឆន្ទៈក្នុងការកាត់ទោសលើមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់នេះ គឺជាទិដ្ឋភាពបែបមនោសញ្ចេតនាមួយដែលបានគ្របដណ្តប់ដំណើរការនីតិវិធីច្បាប់ទាំងស្រុង ដែលគិតចាប់ពីភាពស្ទាក់ស្ទើរក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ពុំគ្រប់គ្រាន់ហួតសេចក្តីសម្រេចដំបូងរបស់តុលាការក្នុងការទម្លាក់ចោលបទចោទនៅក្នុងសំណុំរឿងនោះ កាលពីខែធ្នូ ឆ្នាំ២០១២ ពីការខកខានមិនបានឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នរហូតដល់ការផ្តន្ទាទោសអំពីបទល្មើស ដែលពុំឆ្លុះបញ្ចាំងពីភាពរឹងមាំនៃភស្តុតាង និងសកម្មភាពដ៏ធ្ងន់ធ្ងររបស់ជនជាប់ចោទ និងការខកខានជាបន្តរបស់អាជ្ញាធរក្នុងការចាប់ខ្លួនជនជាប់ចោទ ទាំងអស់នេះ ជាការបង្ហាញពីនិទណ្ឌទោសយ៉ាងច្បាស់ចំពោះមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលដែលរំលោភបំពានលើក្រមព្រហ្មទណ្ឌ។ ផ្ទុយទៅវិញ សហជនជាប់ចោទត្រូវបានផ្តន្ទាទោសដើម្បីជាវិធីមួយក្នុងការបង្វែរចំណាប់អារម្មណ៍របស់សាធារណជនពីការដាក់បន្ទុកលើជនជាប់ចោទ ទោះបីជាមានភស្តុតាងតិចតួច ឬពុំគួរជឿជាក់ប្រឆាំងនឹងគាត់ក្តី និងដើម្បីបន្ធូរបន្ថយសម្ពាធពីសាធារណៈជនដោយពុំត្រឹមត្រូវ។ម្យ៉ាងវិញទៀត តំណាងមហាអយ្យការ និងចៅក្រមសាលាឧទ្ធរណ៍បានត្រឹមតែចេញសាលដីកាសម្របតាមសាលក្រមដែលបានធ្វើឡើងដោយសាលាដំបូងខេត្តស្វាយរៀងតែប៉ុណ្ណោះ។

ផ្អែកលើការវិភាគនៃភស្តុងតាងខាងលើ និងប្រសិនបើជនជាប់ចោទត្រូវប្រព្រឹត្តដោយត្រឹមត្រូវ និងឥតលម្អៀងពីសំណាក់ព្រះរាជអាជ្ញា និងតុលាការកម្ពុជានោះ ម្លេះករណីរបស់ជនជាប់ចោទគួរតែត្រូវបានចោទប្រកាន់ពីបទ "*ប៉ុនប៉ងមនុស្សឃាត*" ឬក៏ យ៉ាងហោចណាស់ពីបទ "*ហិង្សាដោយចេតនា*" ដោយមានស្ថានទម្ងន់ទោសតាមរយៈការប្រើប្រាស់អាវុធ។ មានតែផ្អែកលើហេតុផលនេះទេដែលជនរងគ្រោះដោយការបាញ់ប្រហារអាចទទួលបានសំណងជួសជុលការខូចខាតយ៉ាងត្រឹមត្រូវចំពោះរបួសស្នាមដែលជនជាប់ចោទបានបង្កមកលើពួកគេ។

ករណីរបស់លោក ឈូក បណ្ឌិត ជាការរម្លឹកថា ប្រព័ន្ធយុត្តិធម៌កម្ពុជា ពុំទាន់មានសេរី និងមានយុត្តិធម៌នៅឡើយទេ។ មានប្រព័ន្ធយុត្តិធម៌ពីរនៅកម្ពុជាបច្ចុប្បន្ននេះ៖ ប្រព័ន្ធយុត្តិធម៌ទីមួយប្រើសម្រាប់ជនមានអំណាច និងជនដែលមានទំនាក់ទំនងស្និទ្ធជាមួយនឹងអ្នកមានអំណាច និង ប្រព័ន្ធយុត្តិធម៌មួយទៀតប្រើសម្រាប់មនុស្សដទៃទៀត។ ការចោទប្រកាន់ និងការផ្តន្ទាទោសលើលោក ឈូក បណ្ឌិត ជាការមើលស្រាលជាខ្លាំងដល់ភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់គាត់ ហើយបើទោះជា ត្រូវបានតុលាការផ្តន្ទាទោសហើយក្តី ក៏លោក ឈូក បណ្ឌិត នៅមិនទាន់ត្រូវបានអាជ្ញាធរចាប់ខ្លួន ដោយនៅមានសេរីភាពដើរហើរនៅឡើយ។ ទន្ទឹមនឹងនេះដែរ ប្រជាពលរដ្ឋផ្សេងទៀត ដូចជា សកម្មជនដីធ្លី អ្នកស្រី យ៉ោម បុប្ផា ដែលបានជាប់ពន្ធនាគារ ហើយដែលបានចំណាយពេលរហូតដល់ ៤៤៥ ថ្ងៃនៅក្នុងពន្ធនាគារសម្រាប់សកម្មភាពរបស់ខ្លួនដែលគ្មានអ្វីក្រៅតែពីការអនុវត្តន៍សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ ត្រូវទទួលរងផលវិបាកដែលកើតចេញពីប្រព័ន្ធតុលាការមិនមានភាពយុត្តិធម៌ ដែលនៅតែបង្កើតនូវវប្បធម៌និទណ្ឌភាពនៅប្រទេសកម្ពុជាដដែល។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក តាមរយៈទូរសព្ទ +៨៥៥(០) ១២ ៤០ ៤០ ៥១ ឬតាមរយៈអ៊ីម៉ែល៖ ouvirak@cchrcambodia.org ឬ តាមរយៈលោកស្រី អូឡា ខេលី ទីប្រឹក្សា ម.ស.ម.ក តាមរយៈទូរសព្ទ៖ +៨៥៥ (០) ៦៧ ៧២ ៧០ ២៥ ឬតាមរយៈអ៊ីម៉ែល៖ orla.kelly@cchrcambodia.org។**